# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយជំនឿខាងសាសនា និងអក្សរសាស្ត្រ

INSTITUT BOUDDHIQUE

ឆ្នាំទី ២៦ ខែមិថុនា លេខ ៦

ព.ស. ២៤៩៧ — គ.ស. ១៩៥៤

# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ

បោះពុម្ពផ្សាយអំពីពុទ្ធសាសនបណ្ឌិត្យ

| ផ្នែកសាសនា | បញ្ជីរឿង | ទំព័រ |
|---|---|---|
| — បកិណ្ណកកថា .................... | ព្រះមហា ផោក-យិប ...... | ៤០៣ |
| — បញ្ញាសជាតក ភាគទី ២ (តមក) .... | បណ្ឌិតមហា ឈឹម-ស៊ុម .. .. | ៤១៣ |

| ផ្នែកអក្សរសាស្ត្រ | | |
|---|---|---|
| — រឿងសៅរ៍សោយ (តមក) ...... .. | ព្រះមហាឧត្តមវិជ្ជា ប៊ុង-ប៉ម .. | ៤៣៥ |
| — រឿងសាមកុក (តមក) ..... ..... | ឧកញ៉ា នូ-កន ......... | ៤៤២ |
| — ទាលៈនឹងទមយន្តី (តមក) .. ...... | អ្នកស្រី ស៊្រុន-សារិយ៉ាន់ .... | ៤៥១ |
| — ដំណឹងតាមខ្យល់ក្នុងកន្តារៈ (តមក) .... | លោកផេង-ជ្រីវ ... ..... | ៤៥៨ |
| — បរិយាយពីសិល្បៈខ្មែរ លើកទី ៣-៤-៥ (តចប់) ................... | លោក ចាប-ពិន ....... | ៤៦៤ |

| កំណត់នៃប្រវត្តិការណ៍ | | |
|---|---|---|
| — បុណ្យមាឃបូជានៅសាលាស្រុកក្រូចឆ្មារ . | ព្រះមហា ជា-អៀន ....... | ៤៧៦ |

មួយឆ្នាំមាន ១២ សៀវភៅ — ដំឡៃជាវ ២០០រ.០០

# KAMBUJASURIYA

Revue religieuse et littéraire éditée par l'Institut Bouddhique

## TABLE DES MATIÈRES

PARTIE RELIGIEUSE: Page

— Pakinnakakatha . . . . . . . *Brah Maha PHOK-YIP* . . . . 403

— Pannasajataka vol-II (suite) . *M. CHHIM-SOUM* . . . . . . 413

PARTIE LITTERAIRE:

— Le « SAU-SOY » ou l'influence saturnienne (suite) . . . . . *Brah Maha PEUNG-PAM* . . . 435

— Histoire de Samkok (suite) . . *Oknha NOU-KAN* . . . . . . 442

— Nala et Damayanti (suite) . . *Mme SRIN-SARIS-YANN* . . . 451

— Le souffle du désert (suite) . *M. PHENG-CHRIV* . . . . . . 458

— Sur les Beaux-Arts khmèrs (suite et fin) . . . . . . . *M. CHAP-PIN* . . . . . . . . 464

NOTES ET CHRONIQUES:

— Maghapuja à Kroch-Chhmar . *Brah maha CHEA-ŒUN* . . . 476

Prix d'abonnement annuel (comprenant 12 numéro) 200$

បកិណ្ណកគាថា

# ព្រះមហា ផោក-យិប សិស្សសាលាបាលីជាន់ខ្ពស់

រៀបរៀង

---

នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ។

*សូមនមស្ការចំពោះព្រះភគវន្តមុនី ជាអរហន្តសម្មាសម្ពុទ្ធព្រះអង្គនោះ (ដោយសេចក្ដីគោរព) ។*

*វេលានេះ អាត្មាភាពសូមពណ៌នាសេចក្ដីក្នុងបកិណ្ណកគាថាដូចមានសេចក្ដីតទៅនេះ ៖*

១ — សុខស្សានុគ្គិ ទុក្ខំ *ទុក្ខកើតក្នុងលំដាប់នៃសុខ*

២ — អជ្ជេវ កិច្ចមាតប្បំ *គួរធ្វើសេចក្ដីព្យាយាមក្នុងថ្ងៃនេះឲ្យហើយទៅ*

៣ — សតិ សព្វត្ថ បត្ថិយា *សតិគឺបុគ្គលគប្បីប្រាថ្នាក្នុងទីទាំងពួង ។*

*បណ្ដាសត្វទាំងឡាយក្នុងពិភពលោកនេះ មានច្រើនបែបមានប្រភេទផ្សេងៗគ្នា ដោយសញ្ជាតិខ្លះ ដោយភាសាខ្លះ ដោយវង្សត្រកូលខ្លះ, បើទុកជាច្រើនដូច្នោះក៏ពិត តែគង់មានការប្រាថ្នាសេចក្ដីសុខដូចៗ*

គ្នា, សមដូចពុទ្ធភាសិតក្នុងគម្ពីរធម្មបទ ខុទ្ទកនិកាយថា សុខកាមានិ ភូតានិ "សត្វទាំងឡាយ ជាអ្នកប្រាថ្នានូវសេចក្ដីសុខគ្រប់ៗគ្នា" ។

ហេតុដូច្នោះ បានជាសត្វទាំងឡាយ ស្វែងរកសេចក្ដីសុខដោយសព្វៗខ្លួន, តែការបានសេចក្ដីសុខមិនដូចគ្នាទេ សត្វខ្លះបានយ៉ាងធំទូលាយ សត្វខ្លះបានយ៉ាងកណ្ដាល សត្វខ្លះបានយ៉ាងស្ដួចស្ដើង សត្វខ្លះត្រឡប់ជាបានទុក្ខវិញក៏មាន ។ ចំណែកមនុស្សវិសេសជាងសត្វតិរច្ឆានទាំងឡាយ ព្រោះមានបញ្ញាជាប់មកអំពីកំណើតដែលហៅថា សជាតិកបញ្ញាផង ព្រោះមានបញ្ញាដែលកើតឡើងអំពីការស្ដាប់ ការគិត ការចំរើនក្នុងបច្ចុប្បន្នផង ឯសត្វតិរច្ឆានមិនមានបញ្ញានេះឡើយ ទើបធៀបនឹងមនុស្សមិនបាន សូម្បីក្នុងពពួកមនុស្សដែលមានបញ្ញាច្រើនជាងសត្វតិរច្ឆាននោះ ក៏នៅមានតិចច្រើនជាងគ្នាជាលំដាប, អ្នកមានបញ្ញាតិចដែលហៅថាទុម្មេធជន ធៀបនឹងសុមេធជនគឺជនអ្នកមានប្រាជ្ញាច្រើនពុំបាន ទុម្មេធជនកាលបើជួបប្រទះសេចក្ដីសុខ ក៏រីករាយសោមនស្សហួសប្រមាណ កាលបើជួបប្រទះសេចក្ដីទុក្ខ ក៏តូចចិត្តទោមនស្សទាល់តែក្ស័យខ្លួន; ចំណែកសុមេធជន មិនដូច្នោះទេ បើទុកជាបានជួបប្រទះសេចក្ដីសុខក្ដីទុក្ខក្ដី, រមែងមិនប្រែសោមនស្សនឹងទោមនស្សឲ្យហួសប្រមាណ, ព្រោះបុគ្គលនោះយកសេចក្ដីសុខទុក្ខនោះមកពិចារណាជាអារម្មណ៍ដោយឧបាយនៃប្រាជ្ញាថា "សេចក្ដីសុខទុក្ខនេះ ជា

លោកធម៌ មិនទៀង អាចឲ្យផលផ្លាស់ប្តូរវេនគ្នាម្តងមួយបែប" ។ សេចក្តីនេះសមដូចវចនប្រព័ន្ធទី ១ ថា: សុខស្សានន្តរំ ទុក្ខំ "ទុក្ខកើតក្នុងលំដាប់នៃសុខ" ។

អធិប្បាយថា: ទុក្ខនឹងសុខជាគូនឹងគ្នា រមែងផ្លាស់ប្តូរវេនគ្នាឲ្យផលម្តងម្នាក់, ជួនកាលក៏ទុក្ខ ជួនកាលក៏សុខ. ទុក្ខនឹងសុខជាធម្មជាតមាននៅប្រចាំគតិធម្មតា, បុគ្គលនឹងប្រាថ្នាយកតែសុខដោយចំណែកមួយពុំបាន, ព្រោះខុសនឹងគតិធម្មតា ។

ព្រោះហេតុនោះ ក្នុងខណៈណាដែលបុគ្គលបានសោយសុខ ជាផលហើយ បន្ទាប់អំពីនោះគង់នឹងបានសោយទុក្ខពុំខាន, ដូច្នេះវេលាដែលជួបប្រទះសុខនឹងទុក្ខ បុគ្គលមិនគួរប្រើសោមនស្ស ឬទោមនស្សឲ្យហួសប្រមាណឡើយ ។ សេចក្តីនេះសមដូច ព្រះកតវុទ្ធមុនីសាស្តាចារ្យទ្រង់ប្រដៅកិក្ខុទាំងឡាយក្នុងសាសនមណ្ឌល ឲ្យមានសតិពិចារណាក្នុងលោកធម្មសូត្រថា ឧប្បន្នំ ខោ មេ ឥទំ សុខំ "សុខនេះកើតដល់អាត្មាអញហើយហ្ន៎!" តញ្ច ខោ អនិច្ចំ ទុក្ខំ វិបរិណាមធម្មំ "តែសុខនោះ មិនទៀងទាត់ នឹងក្លាយជាទុក្ខវិញ មានសេចក្តីប្រែប្រួលជាធម្មតា" ។ សូម្បីក្នុងវេលាដែលជួបប្រទះនូវសេចក្តីទុក្ខ ក៏ទ្រង់ត្រាស់ប្រដៅឲ្យមានសតិពិចារណាដោយន័យដូចគ្នាថា ឧប្បន្នំ ខោ —

មេ ឥទំ ទុក្ខំ "ទុក្ខនេះកើតដល់អាត្មាអញហើយហ្ន៎" តញ្ច ខោ អភិភុយ្យ សុខំ វិបរិណាមធម្មំ "តែទុក្ខនោះមិនទៀង នឹងក្លាយជាសុខវិញ មានសេចក្ដីប្រែប្រួលជាធម្មតា" ។

សុមេធជន កាលបើបានជ្រាបលក្ខណៈសុខទុក្ខយ៉ាងនេះហើយ, សុខទុក្ខក៏មិនអាចគ្របសង្កត់ចិត្តបាន, បើទុកជាគ្របសង្កត់បានខ្លះក៏មិនហួសប្រមាណដូចទុម្មេធជនដែរ, កាលបើសុមេធជនខំប្រព្រឹត្តទាល់តែបន្ទោបង់សោមនស្សនឹងទោមនស្សបានហើយ, ព្រះអរហំសម្មាសម្ពុទ្ធទ្រង់ត្រាស់ថា បរិមុច្ចតិ ទុក្ខស្មាតិ វទាមិ "តថាគត ពោលថា បុគ្គលនោះ រមែងរួចស្រឡះចាកទុក្ខបាន" ។

ករណីយកិច្ច ដែលត្រូវប្រតិបត្តិតាមលំអាននៃលោកធម្មសូត្រដើម្បីឲ្យរួចស្រឡះចាកទុក្ខបាននោះ ត្រូវជាអ្នកមិនខ្ជិលច្រអូស, មានសេចក្ដីព្យាយាមមិនលះបង់ធុរៈ ។ សេចក្ដីនេះសមដូចពុទ្ធភាសិតក្នុងខុទ្ទកនិកាយ សុត្តន្តបិដកថា វីរិយេន ទុក្ខមច្ចេតិ "បុគ្គលកន្លងទុក្ខបាន ព្រោះសេចក្ដីព្យាយាម" ។ អធិប្បាយថា សេចក្ដីប្រឹងប្រែង ខ្នះខ្នែង ឧស្សាហ៍ដែលជាបដិបក្ខនឹងសេចក្ដីខ្ជិលច្រអូស, គឺ ភាវៈជាអ្នកអង់អាចមិនខ្លាចចំពោះវិពេធិប្បច្ច័យមានក្ដៅនឹងត្រជាក់ជាដើម ដោយបំណងយ៉ាងមាំថា "អាត្មាអញ នឹងធ្វើករណីយកិច្ចដោយសេចក្ដីព្យាយាម មិនលះ

បង់ធុរៈត្រាតែបានសម្រេចតាមបំណង" ។ ឯសេចក្ដីព្យាយាមនោះបែកជាមាតិកាមាន ៤ ប្រការគឺ សំវរប្បធាន ព្យាយាមសង្រួមបិទទ្វារទាំង ៦ គឺ ភ្នែក, ត្រចៀក, ច្រមុះ, អណ្ដាត, កាយ, ចិត្ត មិនឲ្យលុះក្នុងអំណាចអកុសលធម៌ ដែលជាហេតុធ្វើឲ្យអន្តរាយព្រហ្មចរិយៈ ១, បហានប្បធាន ព្យាយាមលះបង់អកុសលធម៌ទាំងឡាយដែលកើតឡើងហើយ ឲ្យអស់អំពីសន្ដាន ១, ភាវនាបធាន ព្យាយាមចំរើនកុសលធម៌ទាំងឡាយដែលមិនទាន់កើតឡើង ឲ្យកើតឡើង ដែលកើតឡើងហើយឲ្យកាន់តែចំរើនច្រើនឡើង ១, អនុរក្ខនាបធាន ព្យាយាមរក្សាទុកកុសលធម៌ទាំងឡាយ ដែលកើតឡើងហើយមិនឲ្យសាបសូន្យទៅវិញ ១ ។ តែបើបែកដោយបំប្រួញមកទៀតមានត្រឹមតែ ២ ប្រការគឺៈ បហានប្បធាន ១ ភាវនាបធាន ១ ។

បណ្ដាសេចក្ដីអាក្រក់ទាំងពួង ដែលហៅថាៈបាប, អកុសល, ទុច្ចរិត, អករណីយកិច្ច, អធម្មចរិយា, វិសមចរិយា នេះជានាទីរបស់បហានប្បធាន ត្រូវព្យាយាមលះបង់ចោលទាំងអស់ ។

បណ្ដាសេចក្ដីល្អទាំងពួងដែលហៅថា បុណ្យ, កុសល, សុចរិត ករណីយកិច្ច, ធម្មចរិយា, សម្មចរិយា នេះជានាទីរបស់ភាវនាបធាន ត្រូវព្យាយាមចំរើនឲ្យកើតឡើងក្នុងខន្ធសន្ដានទាំងអស់ ។ សេចក្ដី

នេះសមដូចធម្មភាសិតទី ២ ថា អជ្ជេវ កិច្ចមាតប្បំ ."គួរធ្វើសេចក្តីព្យាយាមក្នុងថ្ងៃនេះឲ្យហើយទៅ កុំបង្អង់ទុកដល់ថ្ងៃស្អែក" ។ អធិប្បាយថា ករណីយកិច្ចដែលត្រូវធ្វើក្នុងបឋមវ័យដូចជាការសិក្សាសិល្បវិជ្ជាការដែលចែកដោយឡែកៗពីគ្នាមានអក្សរសាស្ត្រនឹងបតុពិធលេខជាដើម,ត្រូវប្រញាប់ធ្វើឲ្យហើយក្នុងបឋមវ័យ ។ ករណីយកិច្ចដែលត្រូវធ្វើក្នុងមជ្ឈិមវ័យ ដូចជាការស្វែងរកទ្រព្យសម្បត្តិជាដើម ត្រូវប្រញាប់ធ្វើឲ្យហើយក្នុងមជ្ឈិមវ័យ ។ ករណីយកិច្ចដែលត្រូវធ្វើក្នុងបច្ឆិមវ័យ ដូចជាការបំពេញបុណ្យកុសល ដែលជាមិត្រជូនដំណើរទៅបរលោកនាយ ត្រូវប្រញាប់ធ្វើឲ្យហើយមុនពេលដែលខ្លួនយើងមានសមត្ថភាពល្មមធ្វើបាន ។ ដែលថា ឲ្យប្រឹងធ្វើករណីយកិច្ចក្នុងលំដាប់វ័យទាំង ៣ នេះ ជាគ្រឿងបំភ្លឺយោបល់ឲ្យប្រឹងធ្វើ មិនគួរបណ្តែតបណ្តោយ តែមិនទាន់សមនឹងបំណងក្នុងធម្មភាសិតនេះនៅឡើយទេ ព្រោះធម្មភាសិតនេះបង្គាប់ឲ្យធ្វើតែម្តងក្នុងថ្ងៃនេះជាដាច់ខាត, នឹងបង្អង់ទៅថ្ងៃស្អែក ឬខានស្អែកពុំគួរ, ព្រោះបុគ្គលមិនអាចកំណត់បាន ស្មានមិនត្រូវថាមច្ចុរាជគឺសេចក្តីស្លាប់នឹងមកដល់ថ្ងៃណា? កាលបើមច្ចុរាជមកដល់ហើយ បុគ្គលមិនអាចនឹងធ្វើសេចក្តីព្យាយាមក្នុងវេលានោះបានទេ, ព្រោះមិនមែនជាវិស័យ ដែលអ្នកណាមួយនឹងជួយការពារដោយវិធីណាមួយបានឡើយ; សមដូចបាថព្រះគាថាក្នុងមជ្ឈិមនិកាយ មជ្ឈិមបណ្ណាសកថា ន មិយ្យមានស្ស

ភវន្តិ តាណា "សេចក្តីជួយការពារ រមែងមិនមានដល់បុគ្គលអ្នកស្លាប់" ។ បើទុកជាបុគ្គលនេះយករតនវត្ថុ ដ៏មានដំឡៃកាត់ថ្លៃមិនបានទៅសូកបាន់ ឬនេះអង្វរករដោយពាក្យផ្អែមល្ហែមថា "នែមច្ចុរាជ! សូមអ្នកបន្ទន់ចាំថ្ងៃក្រោយសិន" ដូច្នេះ មច្ចុរាជមិនអាចទទួលសំណូក ឬទទួលពាក្យអង្វរយើងឡើយ កាលបើដល់ពេលហើយត្រូវតែស្លាប់ឈប់មិនបាន ។ សេចក្តីនេះសមដូចទេសនាន័យក្នុងមជ្ឈិមនិកាយឧបរិបណ្ណាសកថា ន ហិ នោ សង្គរន្តេន មហាសេនេន មច្ចុនា "ការឈប់សម្រាកនៃសេចក្តីស្លាប់ ដែលមានសេនាដ៏ច្រើននោះមិនមានឡើយ" ។

ព្រោះហេតុដូច្នោះ បុគ្គលគួរធ្វើសេចក្តីព្យាយាមឲ្យហើយក្នុងថ្ងៃនេះ ដោយសេចក្តីមិនប្រមាទ កាលបើចិត្តដែលជាប់ស៊ប់ទៅក្នុងសេចក្តីប្រមាទហើយ ក៏ឈ្មោះថាបើកឱកាសឲ្យអកុសលធម៌ទាំងពួងចូលមកលុកលុយសន្តានរបស់ខ្លួនបាន ។

ម្យ៉ាងទៀត សម្តេចព្រះអនាវរណញ្ញាណ ទ្រង់ប្រៀនប្រដៅក្នុងអប្បមាទកថា ជាអនេកបរិយាយ, ដូចភាសិតបញ្ញាដែលទ្រង់ប្រដៅភិក្ខុទាំងឡាយក្នុងបរិនិព្វានសម័យថា ហន្ទទានិ ភិក្ខវេ អាមន្តយាមិ វោ "ម្នាលភិក្ខុទាំងឡាយ តថាគតសូមដាស់តឿនអ្នកទាំងឡាយ វយធម្មា

សង្ខារា សង្ខារទាំងឡាយមានការវិនាសទៅជាធម្មតា អប្បមាទេន សម្បាទេថ "អ្នកទាំងឡាយចូរញុំាងសេចក្តីប្រតិបត្តិឲ្យដល់ព្រម គឺ ចូរញុំាងសិក្ខាទាំង ៣ គឺ អធិសីលសិក្ខា ១ អធិចិត្តសិក្ខា ១ អធិប្បញ្ញា-សិក្ខា ១ ឲ្យដល់ព្រមដោយសេចក្តីមិនប្រមាទ" ។

ការមិនប្រមាទនេះ បើពោលដោយសេចក្តីអធិប្បាយ គឺការមិនភ្លេចភាំងសតិ, សតិនេះមានឧបការៈច្រើនទូទៅក្នុងគតិលោកនិងគតិធម៌ ។ បុគ្គលដែលប្រកបកិច្ចការផ្សេងៗ បើមានសតិជាមេបញ្ជាការហើយ កិច្ចការនោះៗ រមែងបានផលិតផលយ៉ាងសម្បូណ៌ក្រៃលែងជាងបុគ្គលភ្លេចសតិ; បុគ្គលភ្លេចសតិបើប្រកបកិច្ចការអ្វីៗ ការនោះៗ ក៏មិនសម្រេចផលដោយល្អបានតាមសេចក្តីប្រាថ្នារបស់ខ្លួនទេ; ដូចជារថដែលមិនមាននាយសារថីកាន់កាប់ រមែងជ្រុលជ្រួសហួសផ្លូវដួលបោះឯង; សតិនេះបើមានច្រើនត្រឹមណា ក៏ជាឧបការៈច្រើនត្រឹមនោះ; ធម៌ពួកខ្លះកាលបើមានច្រើន រមែងធ្វើឲ្យមានកង្វល់ ត្រូវមានធម៌ដទៃអែបនែបផងទើបប្រព្រឹត្តទៅដោយស្រួលបួលបាន, ដូចជាសទ្ធា បើមិនប្រកបដោយបញ្ញាផងទេ អាចក្លាយទៅជាអធិមោក្ខ, បញ្ញាបើមិនប្រកបដោយសទ្ធាទេ អាចក្លាយទៅជាវិបរិតផ្តេសផ្តាស; វិរិយ បើមិនប្រកបដោយសមាធិផងទេ អាចធ្វើចិត្តឲ្យរវើរវាយ; សមាធិបើមិនប្រកបដោយវិរិយៈផងទេ អាចធ្វើចិត្តឲ្យខ្ជិលច្រអូស ។ ធម៌ទាំងអម្បាលនេះត្រូវមានស្មើភាគគ្នា ។ ឯសតិ

មិនដូច្នោះទេ, ជាធម៌មានគុណានុភាពអាចប្រព្រឹត្តទៅបានតែឯកឯង ដោយមិនចាំបាច់មានធម៌ដទៃនៅអែបនៃបង់ឡើយ រមែងប្រព្រឹត្តទៅបានក្នុងទីទាំងពួង ។ សេចក្ដីនេះសមដូចទេសនាន័យក្នុងគាថាទី ៣ ថា

សតិ សព្វត្ថ បត្ថិយា "សតិគឺបុគ្គលគប្បីប្រាថ្នាក្នុងទីទាំងពួង" ។

អធិប្បាយថា: ធម្មជាតិមួយយ៉ាង កាលបើបុគ្គលរលឹកហើយ រមែងទប់ចិត្តមិនឲ្យត្រាច់ទៅក្នុងអារម្មណ៍ផ្សេង ៗ និងញុំាងករណីយកិច្ចដែលបុគ្គលកំពុងធ្វើ កំពុងនិយាយ កំពុងគិត មិនឲ្យភ្លាំងភ្លាត់បានហៅថាសតិ; សតិនេះរមែងមានប្រយោជន៍ដ៏ទូលាយក្នុងទីទាំងពួង ដូចឥរិយាបថទាំង ៤ គឺ: ដេក, ដើរ, ឈរ អង្គុយ ត្រូវប្រើសតិជាគ្រឿងរលឹកនៅគ្រប់វេលា; ព្រោះហេតុនោះបានជាក្នុងសំយុត្តនិកាយ សគាថវគ្គលោកពោលសរសើរសតិនេះ ដោយន័យផ្សេង ៗ ថា សតិ លោកស្មិ ជាគរោ សតិជាគ្រឿងរលឹកនៅក្នុងលោក, សតិមតោ សុវេ សេយ្យោ អ្នកមានសតិជាអ្នកប្រសើរគ្រប់ពេល, សតិមតោ សទា ភទ្ទំ អ្នកមានសតិជាអ្នកចំរើនគ្រប់ពេល, សតិមា សុខមេធតិ អ្នកមានសតិរមែងដល់នូវសេចក្ដីសុខ ។ សតិនេះមានគុណសម្បត្តិដូចពណ៌នាមកយ៉ាងនេះឯង ។

ធម៌ដែលសំដែងមកនេះ បើពោលដោយរួបរួមបានសេចក្ដីថា: សុខទុក្ខមិនទៀង រមែងផ្លាស់ប្ដូរវេនគ្នាឲ្យផលម្ដងមួយបែប, ក្នុងពេល

ដែលបុគ្គលបានសោយសុខក្តី ទុក្ខក្តី មិនត្រូវប្រែសោមនស្សនឹងទោមនស្សឲ្យហួសប្រមាណ, ការប្រតិបត្តិដើម្បីធ្វើសេចក្តីទុក្ខឲ្យរលត់បាននោះត្រូវអាស្រ័យសេចក្តីព្យាយាម, ក៏សេចក្តីព្យាយាមនោះគប្បីធ្វើឲ្យហើយក្នុងពេលដែលខ្លួនយើងមានសមត្ថភាពល្មមធ្វើបាន ដោយសេចក្តីមិនប្រមាទ តាមន័យដូចបានរៀបរាប់មកនេះឯង ។

បកិណ្ណកកថា ធម្មទេសនាដែលអាត្មាភាពសំដែងមក ចប់ដោយសង្ខេបតាមគួរដល់វេលាត្រឹមតែប៉ុណ្ណេះ ឯវំ ។

---

**មិត្តគួរគប់**

កិច្ចការណាមួយ ល្អក្តី មិនល្អក្តី គួរជាទីស្អប់ខ្ពើមក្តី ជាទីស្រឡាញ់ពេញចិត្តក្តី បុគ្គលណាប្រាថ្នាសេចក្តីចំរើនដល់អ្នកណា បើទុកជាអ្នកនោះមិនសាកសួរ ក៏ត្រូវតែប្រាប់កិច្ចការនោះដល់អ្នកនោះ ។

បញ្ញត្ត្រ:

# បញ្ញាសជាតក

## ភាគទី ២

បណ្ឌិតមហា ឈឹម-ស៊ុម សាស្ត្រាចារ្យ

នៅសាលាបាលីជាន់ខ្ពស់ បានឲ្យប្រែហើយពិនិត្យផ្ទៀងផ្ទាត់ដោយខ្លួនឯង

កាលដែលនៅជាភេទបព្វជិតពី ព.ស. ២៤៨៦, គ.ស. ១៩៤៣

(តមក)

---

## ចន្ទភជជាតកទី ៨

(និយាយអំពីការលែងសត្វ ប្រគេនទឹកស្រង់ និងប្រទីបបូជាសង្ឃ)

លោកអាចារ្យ ម៉ៀវ-ឆន្ទ ប្រែពីបាលី

---

ន មោចេមីតិ ឥទំ សត្ថា ជេតវនេ វិហរន្តោ សត្តមោចនំ អារព្ភ កថេសិ ។ *សត្ថា គឺអង្គសម្តេចព្រះសព្វញ្ញូបរមសាស្តាចារ្យ កាលទ្រង់គង់នៅវត្តជេតពនមហាវិហារ ទ្រង់ប្រារព្ធនូវការលែងសត្វ ហើយទ្រង់សំដែងព្រះធម៌ទេសនាមានបទព្រះបាលីថា ន មោចេមិ ដូច្នេះជាដើម ។*

*មានសេចក្តីដំណាលថា សម័យថ្ងៃមួយ ភិក្ខុទាំងឡាយអង្គុយប្រជុំគ្នាក្នុងសាលាធម្មសភា ពោលពណ៌នាសរសើរបារមីនៃព្រះបរមគន្តាចារ្យថា “ព្រះបរមសាស្តាជាម្ចាស់យើងរាល់គ្នា ទ្រង់បំពេញបារមី*

ដើម្បីនឹងដោះពួកសត្វទាំងអស់ឲ្យល្ដោះរួចចេញចាកសង្សារទុក្ខ" ។ ភិក្ខុទាំងនោះកំពុងតែនិយាយគ្នាដូច្នេះ ស្រាប់តែសម្ដេចព្រះបរមសាស្ដាទ្រង់ចេញចាកគន្ធកុដិមកកាន់សាលាធម្មសភា ត្រាស់សួរថា "ម្នាលភិក្ខុទាំងឡាយ! អម្បាញ់មិញ អ្នកទាំងឡាយជំនុំគ្នានិយាយពីរឿងអ្វី?" ។ ភិក្ខុទាំងនោះក្រាបបង្គំទូលដំណើរសេចក្ដីដែលខ្លួនប្រជុំគ្នានិយាយ, ទើបព្រះអង្គទ្រង់ត្រាស់ថា "ម្នាលភិក្ខុទាំងឡាយ! តថាគតមិនមែនទើបតែនឹងដោះពួកសត្វក្នុងកាលឥឡូវនេះទេ; កាលពីដើមតថាគតនៅជាពោធិសត្វកំពុងបំពេញបារមី មានញាណមិនទាន់ចាស់ក្លា យាត្រាទៅក្នុងសមុទ្រជាមួយនឹងពួកឈ្មួញ ក៏ធ្លាប់បានសង្គ្រោះដោះទុក្ខសត្វទាំងឡាយដូច្នេះដែរ" ។ ទ្រង់មានព្រះពុទ្ធដីកាតែប៉ុណ្ណោះ ក៏គង់ស្ងៀមត្រាតែភិក្ខុទាំងនោះអារាធនា ទើបទ្រង់នាំអតីតនិទានមកសំដែងប្រាប់ថាៈ

អតីតេ ភិក្ខវេ ពារាណសិយំ ឯកោ វាណិជោ ធនកោ នាម បដិវសតិ ។ ភិក្ខវេ ម្នាលភិក្ខុទាំងឡាយ! ក្នុងកាលកន្លងរំលងបាត់ស្ងាត់ទៅហើយ មានពាណិជម្នាក់ឈ្មោះធនកៈ នៅនគរពារាណសី មានភរិយាឈ្មោះនាងនន្ទា, ពាណិជនោះជាធំជាងពួកពាណិជទាំង ៥០០ ។ គ្រានោះ ព្រះពោធិសត្វទ្រង់គង់នៅក្នុងទេវលោកជាន់តាវត្តិង្ស លុះអស់ព្រះជន្មាយុ ក៏ច្យុតចាកទីនោះ មកចាប់បដិសន្ធិក្នុងផ្ទៃនៃនាងនន្ទា ។ គ្រាដែលនាងមានគភ៌គ្រប់ ១០ ខែ ក៏ឃើញសុបិន

និមិត្តកន្លងវេលាបច្ចូសសម័យថា មានតាបស ១ រូប ហោះទៅតាមអាកាស ប
ចាប់មណ្ឌលព្រះចន្ទ្រ កាន់យកមកដាក់លើព្រះហស្តនាង ។ នាង
ភ្ញាក់ចាកនិទ្រាឡើង ក៏ប្រសូតបុត្រហើយនាងមានចិត្តត្រេកអរថា "អញ
បានកូនប្រុសដ៏ប្រសើរ សមដូចសុបិននិមិត្តដែលបានឃើញ" ។ ទើបគេ
ប្រជុំក្រុមញាតិវង្សមកកំណត់នាមឲ្យបុត្រនោះហៅថា ចន្ទកុមារ ព្រោះ
ពេលមុនប្រសូត មាតាយល់សប្តិឃើញបានព្រះចន្ទ្រ ។

លុះដល់ចន្ទកុមារមានវ័យចំរើនធំឡើង មានរូបឆោមលោមពណ៌ល្អ
ស្រស់ដូចមាស ពង់ពៅសមរម្យពុំមានធ្លង អ្នកផងតែងរាប់អានស្រឡាញ់
ពេញចិត្តកល់ៗគ្នា លុះបានជន្មាយុ ១៦ វស្សា ក៏រៀនចេះចប់សព្វ
សិល្បសាស្ត្រគ្រប់យ៉ាង ។ កាលនោះ មានពួកពាណិជ ៥០០ នាក់
កំពុងប្រុងប្រៀបរៀបដំណើរ នឹងទៅជួញឯស្រុកសុវណ្ណភូមិ ។ ចន្ទកុមារ
ចូលទៅក្រាបសំពះលាមាតាបិតាថា "បពិត្រអ្នកម្តាយអ្នកឪពុក! ខ្ញុំនឹង
សុំទៅជួញឯស្រុកសុវណ្ណភូមិ ជាមួយនឹងពួកឈ្មួញទាំងឡាយ" ។
មាតាបិតាបានឮហើយក៏ឃាត់ថា "កូនអើយ! អ្នកកុំចេញចោលយើង
ទៅជួញជាមួយនឹងពួកឈ្មួញឡើយ, កូនអើយ! ធម្មតាសមុទ្រ ចួនកាល
ក៏ស្រួល ចួនកាលក៏មិនស្រួលទេ, ច្រើនតែប្រទះលើសេចក្តីអន្តរាយ,
ចូរកូនអ្នកកុំទៅឡើយ" ហើយពោលនូវគាថានេះថា៖

ហាហា បិយបុត្តក ហាហា បិយហទយក

## មា តោ បហាយ បុត្តក តាត មា គោវ ធទ្ធហិ

ឱកូនសំឡាញ់អើយ! ឱកូនសំឡាញ់ខណ្ឌលចិត្តអើយ!

កូនអើយ! អ្នកកុំលះបង់យើងទាំងពីរទៅឡើយ, ម្នាលកូន!

អ្នកកុំបោលយើងទាំងពីរណា ។

មហាសត្តបុះនស្ដាប់ពាក្យមាតាបិតាៈហើយ ក៏ឆ្លើយតបទៅវិញយ៉ាង នេះថា "បពិត្រមាតាបិតា! សូមលោកកុំឃាត់ខាំងរាំងកទៀយ, ខ្ញុំបាទនឹងទៅជាមួយពួកឈ្មួញពុំខាន" ។ មាតាបិតាពុំអាចឃាត់កូនបាន ក៏ព្រមអនុញ្ញាតឲ្យទៅ ។ ចន្ទកុមារក្រាបថ្វាយបង្គំមាតាបិតាដោយបញ្ចង្គប្រតិស្ឋាន ហើយយកទ្រព្យសំរាប់ធ្វើដើមទុន ឡើងកាន់សំពៅទៅជាមួយនឹងពួកឈ្មួញ ក្នុងថ្ងៃមានឫកល្អ, សំពៅត្រូវខ្យល់ខ្លាំងបក់ផាត់មកក៏លឿនរលោរលាំ៦ឆ្នាំទន្ទេងទៅកណ្ដាលសមុទ្រ ចូងផុតដក់ត្រើយមួយកន្លែងបានឃើញពួកមនុស្សដើរចូលទៅកាន់ផ្សារ ក៏ចុះចាកសំពៅទៅនឹងគេ, បានឃើញពួកមហាជនលក់សត្វរស់ក៏ទិញកណ្ដុរនឹងស្វាក្រែកជាច្រើនយកមកដាក់សំពៅ, កាលបើបើកសំពៅទៅដល់ត្រើយសមុទ្រមួយកន្លែងដទៃទៀត, មើលទៅឃើញផ្សារដែលមហាជនចេញចូលត្រៀបត្រាក៏ចូលទៅកាន់ផ្សារនោះនឹងគេទៀត, ទិញទន្សាយនឹងពសជាច្រើនដាក់សំពៅហើយចេញទៅ ។ ឯពួកឈ្មួញផងគ្នា បានឃើញសត្វទាំងនោះ ក៏សួរថា "នែចន្ទកុមារ! អ្នកទិញសត្វនេះទៅធ្វើអ្វី?" ។

ចន្ទកុមារប្រាប់ថា "ខ្ញុំទិញយកទៅលែង" ។ ទើបពួកឈ្មួញនិយាយទូន្មានថា "ម្នាលចន្ទកុមារ! ធម្មតាឈ្មួញ តែចុះមកកាន់សំពៅហើយ គេតែងប្រឹងប្រែងសង្វាតរកទ្រព្យ, ចុះបើអ្នកឯងទិញតែសត្វទាំងនេះយកទៅលែង មិនបង់ខាតសោហ៊ុយឥតអំពើទេឬ? អ្នកឯងល្ងង់អ្វីម៉្លេះ" ។ ចន្ទកុមារឮដូច្នោះហើយក៏តបវិញថា "បពិត្រពាណិជទាំងឡាយដ៏ចំរើនអើយ! ខ្ញុំមិនមែនល្ងង់ទេ, អ្នកលក់គ្នាទេតើ ជាមនុស្សល្ងង់, បានជាខ្ញុំថាដូច្នោះ ព្រោះជនអ្នកលែងសត្វ តែងបានអានិសង្សមានអាយុយឺនយូរជាដើមផង បានសេចក្ដីសរសើរផង, អ្នកប្រាជ្ញទាំងឡាយតែងសរសើរទូវបណ្ដាជនដែលលែងសត្វ ថាជនអ្នកលែងសត្វចាត់ជាអ្នកមានបុណ្យ តែងបានសោយសេចក្ដីសុខផង, ឯអ្នកដែលពុំបានលែងសត្វចាត់ជាអ្នកឥតបុណ្យ តែងជួបប្រទះនឹងសេចក្ដីវិនាសធំ ខ្ញុំយល់ដូច្នេះបានជាខ្ញុំទិញសត្វយកទៅលែង" ។ ពួកពាណិជឃាត់ចន្ទកុមារមិនឈ្នះក៏នាំគ្នាធ្វើដំណើរទៅទៀត ។ កាលបើសំពៅល្បឿនហួសពីនោះទៅព្រះមហាសត្វក្រឡេកទៅខាងឆ្នេរសមុទ្រ បានឃើញកោះមួយធំក៏នឹកក្នុងចិត្តថា "លើកោះនេះប្រហែលជាមានសមណៈអ្នករក្សាសីលត្រឹមត្រូវ បើអាត្មាអញយកសត្វទាំងនេះទៅលែងក្នុងសំណាក់លោកនោះ ឃើញថាជាការគាប់ប្រសើរ" គិតយ៉ាងនេះហើយ ក៏យកសត្វឡើងទៅលើកោះ ។

កាលនោះ មានព្រះថេរៈមួយអង្គសព្វព្រះទ័យនៅដោយការស្ងប់ស្ងាត់ លោកគង់ចំរើនភាវនាលើភ្នំនោះ ។ ព្រះមហាសត្វបានឃើញព្រះថេរៈនោះ ក៏មានចិត្តរីករាយ ចូលទៅថ្វាយបង្គំដោយបញ្ចង្គប្រតិស្ឋាន ហើយសួរថា "បពិត្រព្រះករុណាដ៏ចំរើន! លោកម្ចាស់មកគង់នៅទីនេះដើម្បីប្រយោជន៍អ្វី?" ។ ព្រះថេរៈបានឮពាក្យមហាសត្វនោះហើយប្រាប់ថា 'ម្នាលឧបាសក! អាត្មាមកនៅទីនេះដើម្បីធ្វើវិវេកគឺសេចក្ដីស្ងប់ស្ងាត់' ។ មហាសត្វឃើញព្រះថេរៈបែកញើសស្រោកពាសពេញទាំងខ្លួនក៏ទូលថា "បពិត្រព្រះករុណាដ៏ចំរើន! ខ្ញុំព្រះករុណាចង់ធ្វើបុណ្យ (បន្តិច)" ។ ព្រះថេរៈថា "ចំរើនពរ អ្នកធ្វើចុះ" ។ មហាសត្វទៅដងទឹកបានចំនួន ៨ ក្អមយកមកប្រគេនលោកស្រង់ រួចហើយប្រគេនស្លាម្ភូរភេសជ្ជប្បច្ច័យបាយទឹក ឧជប្រទីប ៨ ដួងបូជាព្រះថេរៈ, យកអស់ទាំងសត្វដែលខ្លួនទិញនោះមកលែងក្បែរលោក ហើយលើកកំបង់ផ្គងអញ្ជលីតាំងសេចក្ដីប្រាថ្នា ពោលនូវគាថានេះថា៖

ភន្តេ ថេរ វរុត្តម សុណាហិ មម វចនំ
ពន្ធនា សត្តមោចនំ បុញ្ញកម្មំ កតំ មយា
ឥមិនា បុញ្ញកម្មេន ពុទ្ធោ ហេស្សាម្យនាគតេ
ជាត្យណ្ណវំ តរិស្សាមិ សន្តារេស្សំ សទេវកំ
ធម្មនាវំ សមារុយ្ហ ឧទ្ធរិស្សាមិ ជនតំ

បពិត្រព្រះករុណាម្ចាស់ដ៏ចំរើន! សូមព្រះគុណម្ចាស់ស្ដាប់ពាក្យខ្ញុំព្រះករុណា ៗ ធ្វើបុណ្យលែងសត្វ ឲ្យរួចពីចំណង់នេះ សូមឲ្យបានត្រាស់ជាព្រះពុទ្ធក្នុងអនាគតកាល ធ្លង់រួចពីអន្ទង់គឺជាតិដោយខ្លួនឯង ហើយចម្លងពួកមនុស្សទាំងទេវតាឲ្យធ្លង់ដោយសារបានផង សូមឲ្យខ្ញុំបានជិះធម្មនាវា (សំពៅពោលគឺធម៌) បើកស្រង់ពួកបណ្ដាជនផង ៗ

បេរោ តស្ស វិចនំ សុត្វា ព្រះថេរៈបានឮដូច្នោះហើយក៏កើតពយសោមនស្សស្មោះសរត្រេកអរ អនុមោទនាពោលនូវគាថានេះថា៖

យំ យញ្ញ បដ្ឋិតំ តយ្ហំ តំ តំ សព្វំ សមិជ្ឈតុ
ឥមិនា បុញ្ញកម្មេន ពុទ្ធោហោហិ អនាគតេ
ជាតណ្ណវំ តរិត្វាន សត្តាពេហិ មហាជនំ
ធម្មនាវំ សមារុយ្ហ បាបុណិស្សសិ និព្វានំ

សេចក្ដីប្រាថ្នាឯណាដែលអ្នកតាំងឡើងហើយ សេចក្ដីប្រាថ្នានោះចូរសម្រេចគ្រប់ប្រការចុះ, ដោយអំណាចបុញ្ញកម្មនេះចូរឲ្យអ្នកបានត្រាស់ជាព្រះពុទ្ធក្នុងអនាគតកាលចុះ, ចូរអ្នកបានធ្លង់អន្ទង់គឺជាតិ ហើយចម្លងមហាជនឲ្យធ្លង់ដោយសារ

ផងចុះ, អ្នកប្រាកដជានឹងបានឡើងជិះធម្មនាវា បើកបរ សំដៅទៅដល់ត្រើយគឺព្រះនិព្វានពុំខាន ។

មហាសត្វបានធ្វើបុណ្យប៉ុណ្ណោះហើយ ក៏ធ្វើប្រទក្សិណថ្វាយបង្គំព្រះថេរៈដោយបញ្ចង្គប្រតិស្ឋាន លាយាត្រាចុះចាកភ្នំ ឡើងជិះសំពៅទៅជាមួយនឹងពួកពាណិជ ដល់ពាក់កណ្តាលសមុទ្រ សំពៅក៏ឃ្លងឃោងខ្លាំងដោយកំលាំងខ្យល់កាច ។ ព្រះមហាសត្វបានជ្រាបថា "សំពៅមុខជានឹងធ្លាយកណ្តាលសាគរ" ក៏បរិភោគគេជនាហារផ្សេងៗ ដ៏មានឱជារស ហើយយកសំពត់សមកជ្រលក់ប្រេងពូតឲ្យស្រស់ស្លៀកយ៉ាងខ្ជាប់ ។ មហាជនទាំងឡាយភិតភ័យខ្លាចស្លាប់ក៏ស្រែកទ្រហោយំខ្សឹកខ្សួលកល់ៗគ្នា ។ ព្រះមហាសត្វដើរទៅឯក្បាលសំពៅ ឡើងលើដងគោង, កាលសំពៅលិចផុតហើយ ក៏លោតផ្លោះរំលងហ្វូងមច្ឆាហែលរួចទៅ ។ ឯជនដទៃៗសឹងជាចំណីសត្វទឹកមានត្រីជាដើម ។

ថ្ងៃនោះជាថ្ងៃឧបោសថ, មហាសត្វក៏ឡេកមើលទៅអាកាស ដឹងច្បាស់ថាជាថ្ងៃឧបោសថ ក៏ខ្ពុរមាត់ដោយទឹកប្រៃ សមាទានឧបោសថសីល ។

គ្រានោះ ចួនជាព្រះមហាក្សត្រក្នុងដែនសុវណ្ណភូមិ ទ្រង់ប្រឈួនដោយព្រះរោគបៀតបៀន ក៏ទ្រង់ព្រះទិវង្គតទៅក្នុងថ្ងៃនោះ ។ ឯនាងទេពធីតាឈ្មោះមណិមេខលា ដែលលោកបាលមហារាជទាំង ៤ តាំងឲ្យ

ជាអ្នករក្សាសមុទ្រ ។ នាងទេពធីតានោះ មានសេចក្តីរំពឹងគិតថា " អាត្មាអញនឹងហោះទៅរកំងមើលមហាសមុទ្រ" ហើយក៏ហោះសំដៅទៅមហាសមុទ្រនោះ បានប្រទះឃើញមហាសត្វកំពុងតែហែលទឹក ហើយសួរ ជាបទព្រះគាថានេះថា ៖

កោយំ មជ្ឈេ សមុទ្ទស្មឹ អបស្សំ តីរមាវុយ្ហេ
កឹ ត្វំ អត្ថវសំ ញត្វា ឯវំ វាយមសេ ភុសំ

អ្នកណានេះ មកហែលកណ្តាលសមុទ្រធំល្វឹងល្វើយមិនយល់គោះត្រើយយ៉ាងនេះ? អ្នកបានដឹងប្រយោជន៍ដូចម្តេច បានជាប្រឹងព្យាយាមទាំងម្ល៉េះ? ។

មហាសត្វបានឮសំដីនាងទេពធីតានោះក៏តបទៅថា ៖

អហំ និសម្ម វត្តំ លោកស្ម ទេវតេ ត្វំ សុណោហិ មេ
យេ បមជ្ជន្តិ លោកស្មឹ ពហូ បាបសមាកុលា
បាបា តេ អតិក្កមិត្វា តេ គហេត្វា អមុញ្ចិហំ
អត្ថានំ បុញ្ញកម្មេន តរន្តោ សោហិ អាកុលោ
គម្ភីរតោ សមុទ្ទតោ យថាសត្តិ យថាពលំ
វាយមន្តេបិ សាគរន្តំ តីរំ បស្សាមិ ទេវតេ

បពិត្រទេវតា, បូរនាងស្តាប់ខ្ញុំ ខ្ញុំជាអ្នកពិចារណាឃើញកិច្ចវត្តដែលត្រូវប្រព្រឹត្តក្នុងលោក, ជនទាំងឡាយឯណាជាអ្នកធ្វេសប្រហែសច្រើន ច្របូកច្របល់ដោយបាបក្នុងលោកនេះ, ខ្ញុំបានដឹកនាំជនទាំងឡាយនោះឲ្យកន្លងផុតចាកបាប, ខ្ញុំជាអ្នកខ្វល់ខ្វាយដោយបុញ្ញកម្មរបស់ខ្លួន ប្រឹងហែលឆ្លងចាកសមុទ្រដ៏ជ្រាលជ្រៅ តាមសេចក្តីអាច តាមកម្លាំង, បពិត្រនាងទេពធីតា ! ខ្ញុំសាត់អណ្តែតមកក្នុងសមុទ្ររបស់នាង បានជួបនឹងនាង ។

នាងមណិមេខលា បានឮដូច្នោះ ក៏មានចិត្តសោមនស្សត្រេកអរ ចុះទៅបីបមថ្នមពារព្រះពោធិសត្វដូចជាគេក្រសោបអោបបាច់ផ្កា ហោះទៅអាកាសសំដៅទៅកាន់ឧទ្យានក្នុងដែនសុវណ្ណភូមិ ដាក់ព្រះពោធិសត្វលើផែនសិលាជាមង្គលប្រគល់ឲ្យទេវតាក្នុងឧទ្យានបីបាច់ថែរក្សា ហើយនាងចៀសចេញពីនោះបាត់ទៅ ។

ចំណែកខាងពួកអាមាត្យទាំងឡាយ បានធ្វើសរីរកិច្ច ថ្វាយព្រះភ្លើងព្រះបរមសពតាមប្រពៃណី បានបង្ហើយកិច្ចជាស្រេច ។ ឯព្រះមហាក្សត្រនោះ មានព្រះរាជធីតា ១ ព្រះអង្គ នាមនាងសិម្ពលី ។ ក្នុងថ្ងៃទី ៧ ចាប់ពីថ្ងៃដែលបង្ហើយកិច្ចនោះមក ពួកព្រាហ្មណ៍ព្រឹទ្ធបុរោហិតគរីសេនាបតីទាំងឡាយប្រជុំប្រឹក្សាគ្នាថា "ឥឡូវនេះ នឹងរកអ្នកណាមួយដែលមានបុណ្យច្រើន ល្មមសមគួរដល់ព្រះរាជធីតាគ្មានសោះ, បើដូច្នេះ

តើយើងនឹងធ្វើដូចម្ដេច?" ។ ពួកព្រាហ្មណ៍ឆ្លើយឡើងថា "ត្រូវផ្សង បុស្សរថមើល, បើបុស្សរថទៅចំអ្នកណា, អ្នកនោះជាមនុស្សមានបុណ្យ សមនឹងព្រះរាជធីតា នឹងជាទីពឹងពាក់ពំនាក់អាស្រ័យនៃយើងរាល់គ្នាបាន" ។ ការប្រជុំ ក៏បានយល់ព្រមតាមបែបនេះ ។ កាលនោះ ពួកព្រាហ្មណ៍ក៏ចាត់ចែងតែងបុស្សរថ រៀបគ្រឿងបូជា រចនាដោយទង់ជាយនឹងទង់ជ្រុងប្រគំដោយភ្លេងតូរ្យតន្ត្រីមានអង្គ ៥ មានក្បួនហែជាលំដាប់លំដោយទៅតាមក្រោយបុស្សរថនោះ ។ បុស្សរថប្រទក្សិណទីក្រុងហើយ ក៏ចេញអំពីក្រុងសំដៅទៅឧទ្យាន ។ កាលនោះ ព្រះមហាសត្វក៏ពុងតែល្ហិតល្ហៃ អស់កំលាំងតាំងពីកណ្ដាលសមុទ្រ ទទូរផុតព្រះសិរសានិទ្រាលក់ទៅ ។ បុស្សរថទៅដល់ផែនកម្ពលសិលា ដែលព្រះមហាសត្វផ្ទំ ក៏ប្រទក្សិណហើយរង់ចាំក្បែរព្រះបាទា ។ ព្រាហ្មណ៍ម្នាក់បានឃើញមហាសត្វកំពុងលក់ ក៏នឹកថា "អ្នកនេះមានបុណ្យមែនឬទេ? អញនឹងពិនិត្យឲ្យដឹងសិនអេះ" ។ ទើបព្រាហ្មណ៍ពិនិត្យមើលលក្ខណៈត្រង់ព្រះបាទា បានដឹងជាក់ថា "អ្នកនេះមានបុណ្យខ្លាំងណាស់ អាចសោយរាជសម្បត្តិគ្រប់គ្រងទ្វីបទាំង ៤ បាន" កាលដឹងដូច្នេះហើយក៏បង្គាប់ពួកក្មេងឲ្យលេងតូរ្យតន្ត្រីអឹងកាប់ស័ព្ទកងរំពង ហើយអញ្ជើញមហាសត្វថា "បពិត្រអ្នកមានបុណ្យច្រើន ជាម្ចាស់! រាជសម្បត្តិត្រូវបានព្រះអង្គហើយ, សូមព្រះអង្គទទួលដំណែង ជាព្រះរាជារបស់យើងខ្ញុំទាំង

ឡាយ គង់កាលឥឡូវនេះ" ។ មហាសត្តបានឮហើយ ក៏ក្រោកឡើង អង្គុយពែនភ្នែនសួរព្រាហ្មណ៍ថា "ម្នាលព្រាហ្មណ៍ដ៏ចំរើន! ចុះស្តេចរបស់អ្នកទៅណា?" ។ ព្រាហ្មណ៍ឆ្លើយថា "សូមទ្រង់ព្រះមេត្តាប្រោស! ព្រះអង្គទ្រង់ទិវង្គតហើយ" ។ មហាសត្តសួរថា "ព្រះអង្គឥតព្រះព្រះរាជបុត្រា-បុត្រីទេឬ?" ។ ព្រាហ្មណ៍ឆ្លើយថា "បពិត្រព្រះសម្មតិ-ទេព! ព្រះរាជបុត្រាគ្មានទេ មានតែព្រះរាជបុត្រី ១ អង្គ" ។ ព្រះមហាសត្ត ក៏ព្រមទទួលរាជសម្បត្តិ ។ ទើបព្រាហ្មណ៍និងអាមាត្យទាំងឡាយ អញ្ជើញព្រះអង្គឡើងគង់ព្រះរាជរថ ដ៏វិចិត្រថ្កើងថ្កាន មានបរិវារណែនណាន់តាន់តាប់ ហែហមនាំព្រះអង្គមកនគរ ។ លុះដល់ទីក្រុងហើយ ស្តេចឡើងលើប្រាសាទគង់លើរាជាសនៈ ក្រោមស្វេតច្ឆត្រដែលគេលើកឡើងបាំងថ្វាយ, អាមាត្យទាំងឡាយថ្វាយរាជ-សម្បត្តិព្រមទាំងព្រះនាមថា ព្រះបាទចន្ទរាជ ហើយនាំនាងសិម្ពលីទេវីជាស្ត្រីចំបងជាងពួកស្រី ១៦ ពាន់ មកតាំងជាព្រះអគ្គមហេសី ។ ព្រះនាងសិម្ពលីនោះ បានជាទីសំណប់សព្វព្រះរាជហឫទ័យនៃព្រះរាជាជាងស្រីឯទៀតៗទាំងអស់ ។ ព្រះកិត្តិយសរបស់ព្រះរាជា ក៏រមែងចំរើនទូលំទូលាយឡើងជាលំដាប់ ។ ចាប់តាំងពីទ្រង់ទទួលរាជសម្បត្តិជាមហាក្សត្រមក ទ្រង់ប្រកបដោយធម៌ដ៏ស្មើ មិនប្រើអាជ្ញាសស្ត្រាវុធមានព្រះទ័យខ្វល់ខ្វាយដោយបុញ្ញកម្ម ទ្រង់បរិច្ចាគមហាទានសព្វវេលា

ទ្រង់អញ្ជើញព្រះបរមរាជបិតានិងព្រះរាជជននី ពីនគរពារាណសីមក ទ្រង់ទំនុកបំរុងដោយសុខសួស្តីសិរីភាព ។

ថ្ងៃ ១ ទ្រង់មានព្រះរាជហឫទ័យរីករាយដោយបីតិ ចាប់ក្តឹកទឹកដល់សត្វដែលទ្រង់ដោះលែងថា “ឱ! បុណ្យរបស់អញនេះ សម្រេចផលទាន់ហន់ណាស់តើ!” ។

គ្រានោះ ដោយផលានិសង្ស ដែលព្រះអង្គបានជូនទឹក ៨ ក្អម ប្រគេនព្រះថេរៈស្រង់ លើកំពូលភ្នំ, លុះបានសោយរាជសម្បត្តិកាលណា ពួកទេវតាតែងទៅជូនទឹកយ៉ាងថ្លា មានក្លិនក្រអូប ចំនួន ៨ ម៉ឺន ៤ ពាន់ក្អមពីស្រះអនោតត្តមកថ្វាយស្ដេចស្រង់ ត្រង់ព្រះលាន រៀងរាល់ថ្ងៃ ៗ ដោយអានុភាពនៃការបូជាប្រទីប ៨ ដួង ពួកទេវតាតែងអុជប្រទីប ៨ ម៉ឺន ៤ ពាន់បូជារាល់ៗថ្ងៃ ៗ ដោយអានុភាពនៃការដោះលែងសេក ពួកសេក ៨ ម៉ឺន ៤ ពាន់ តែងពាំនាំយកស្រូវសាលីអំពីព្រៃហេមពាន្ត មកបូជាព្រះអង្គរាល់ៗថ្ងៃ ៗ ដោយអានុភាពនៃការដោះលែងខ្លាឃ្មុំ, ពួកខ្លាឃ្មុំ ៨ ម៉ឺន ៤ ពាន់តែងនាំយកផ្កាទាំងឡាយមានផ្កាចង្កុលណីជាដើម អំពីព្រៃហិមពាន្តមកថ្វាយព្រះអង្គ ៗ ដោយអានុភាពនៃការដោះលែងកណ្ដុរ, ពួកកណ្ដុរ ៨ ម៉ឺន ៤ ពាន់តែងទេះសកស្រូវសាលីថ្វាយព្រះអង្គ ៗ ដោយអានុភាពនៃការដោះលែងស្វាក្រែះ មានពួកស្វាក្រែះចំនួន ៨ ម៉ឺន ៤ ពាន់ ទៅបេះផលាផលផ្សេងៗ អំពីព្រៃ

ហិមពាន្ត យកមកបូជាព្រះអង្គពល់ៗថ្ងៃ ៗ ដោយអានុភាពនៃការដោះលែងទន្សោង ពួកទន្សោង ៨ ម៉ឺន ៤ ពាន់តែងទៅបេះផ្កាទុម្ពារ យកមកបូជាព្រះអង្គពល់ៗថ្ងៃ ៗ ដោយអានុភាពនៃការដោះលែងពស់, ពួកពស់ ៨ ម៉ឺន ៤ ពាន់ទៅពាំកែវមណីអំពីសមុទ្រ យកមកថ្វាយព្រះអង្គ ៗ សត្វទាំងឡាយ តែងនាំផ្កាយអំពីទិសផ្សេងៗ មកថ្វាយព្រះអង្គសព្វៗថ្ងៃ ៗ ពួកទេព្តាដទៃ ក៏នាំយកគ្រឿងសក្ការបូជាមកថ្វាយព្រះអង្គ ៗ ទាំងស្តេច ១០១ ព្រះអង្គក្នុងសកលជម្ពូទ្វីប ក៏សឹងនាំយកគ្រឿងជផ្កាយមកថ្វាយបូជាព្រះមហាសត្វ ៗ តាំងតែពីទ្រង់បានសោយរាជសម្បត្តិ ព្រះមហាសត្វ ទ្រង់ប្រកបដោយព្រះយសខ្ពង់ខ្ពស់អស្ចារ្យ ៗ លុះចំណេរមកខាងក្រោយ ព្រះនាងសិម្ពលីទេវី ទ្រង់ប្រសូតព្រះរាជបុត្រា ១ ព្រះអង្គ ក្រុមព្រះញាតិវង្សថ្វាយព្រះនាមថា មហាលកុមារ ៗ

ឯព្រះមហាសត្វ ទ្រង់សោយរាជ្យជាសុខអស់កាលយូរលង់ក្នុងសុវណ្ណភូមិ លុះដល់ទ្រង់ព្រះជរា ក៏មានបំណងចង់បរិច្ចាគសត្តសតកមហាទាន ទើបទ្រង់ត្រាស់ហៅអាមាត្យឈ្មោះសេនាគុត្ត មកបង្គាប់ថា "ម្នាលប្រស្តែង! ឥឡូវនេះ យើងនឹងឲ្យសត្តសតកមហាទាន, ចូរប្រស្តែងរៀបចាត់ចែងរបស់ ៧ មុខ ក្នុង ១ មុខ ៧០០ គឺ ដំរី ៧០០ សេះ ៧០០ រថ ៧០០ ខ្ញុំស្រី ៧០០ ខ្ញុំប្រុស ៧០០ គោឈ្មោល ៧០០ គោញី ៧០០ ព្រមទាំងគ្រឿងអាហារគោជនផ្សេងៗ ឲ្យបានជា

ប្រញាប់" ។ សេនាគុត្តអាមាត្យ បានទទួលបាត់ការតាមព្រះបង្គាប់ ហើយត្រឡប់មកក្រាបបង្គំទូលព្រះមហាសត្វ. ព្រះអង្គទ្រង់ស្ដេចទៅកាន់ រោងទាន ទ្រង់ព្រះរាជទានសត្តសតកមហាទាន ។ កាលនោះ មានពួក ទេវតាឃោសនាប្រាប់ដល់ពួកស្ដេចទីងសម្ពកងសកលជម្ពូទ្វីបថា "ឥឡូវ នេះព្រះបាទចន្ទរាជ កំពុងព្រះរាជទាននូវមហាទាន អ្នកទាំងឡាយចូរ ទៅទទួលយកកុំបង្អង់" ។ ក្នុងថ្ងៃដែលទ្រង់ព្រះរាជទាននោះ មានពួក ស្ដេចមកពីទិសផ្សេងៗ ដោយទេវតានុភាព មកទទួលយកនាងនារី ហើយចៀសចេញទៅ ។. ពួកសូមយាចកអ្នកកំសត់ មកអំពីទិសផ្សេងៗ ក៏ទទួលយកទ្រព្យធនរៀងរាល់អាត្មា ហើយចៀសចេញទៅ ។ ព្រះ មហាក្សត្រ ទ្រង់ទតព្រះនេត្រយល់ពួកសូមយាចកទទួលព្រះរាជទាន ហើយត្រឡប់ទៅវិញ ក៏មានព្រះរាជហឫទ័យរីករាយស្មោះសារត្រេកអរ លើសលន់ពន់ពេក ។

គ្រានោះដោយតេជានុភាពនៃទាន ដែលព្រះពោធិសត្វទ្រង់បាន បំពេញ ក៏ក្រឡាមហាប្រឹថពីកម្រាស់ ២៤០.០០០យោជន៍ បញ្ចេញ កម្ទេចញាប់ញ័ររំពួររំពួរគម្រាមដូចដំរីចុះប្រេង, ទាំងភ្នំសិនេរុជាស្ដេចបពិត ក៏ទន់ទោរទេទន់ល្វន់ល្វាសដូចជាពុនដំបងទងផ្ដៅ វែរសំដៅទៅរកនគរ សុវណ្ណភូមិ, ទាំងសមុទ្រសាគរក៏រំពើកសន្ទឹកក្ដុកក្ដួរលើកបោកបែកផ្កា ត្រែង, ទាំងព្រះពិរុណក៏បង្អុរចុះគគ្រុកគគ្រឹកពន្លឺកមហិមា ផ្ទុកបន្ទោរក្ដី

ក្តៅក្រហមប្រាលផាលច្រាក់ខ្ចាត់ស្ទើ, តាំងពីផែនដីផ្លូវសុធា រហូតដល់ព្រហ្មលោក សឹងមានការអស្ចារ្យកោលាហលអំពល់តែបែប ១ ដូចគ្នា, តាំងអាសនារបស់សម្តេចអមរិន្ទ្រាធិរាជ ក៏សំដែងអាការក្តៅរំជួលស្ទុះស្ទាប់សាប់សល់ សក្កទេវរាជទឹកពិគាល់ធ្ងល់ក្នុងព្រះចិន្តាពិចារណាមើលហេតុគេទ សង្កេតជ្រាបច្បាស់ថា "ចន្ទកុមារនេះជាពុទ្ធង្កូរបណ្ឌិតសពេជ្ញ ស្តេចកំពុងបរិច្ចាគសត្តសតកមហាទាន, បើដូច្នេះ គួរអញចុះទៅឯមនុស្សលោកសិនអេះ" លុះទ្រង់ព្រះចិន្តាដូច្នេះហើយ ក៏ទ្រង់ឡើងគង់ប្រាសាទវេជយន្តទ្រង់ទតមើលសត្វលោក ហើយហោះ (ចុះចាកឋានសួគ៌ទេវលោក) មកសន្ធិតនៅខាងមុខប្រាសាទព្រះមហាសត្វ ។ ព្រះបាទចន្ទរាជទ្រង់មានព្រះរាជឱង្ការត្រាស់សួរទៅព្រះឥន្ទ្រាធិរាជ ដោយបទព្រះគាថានេះថា ៖

កឹ វិមានំ បុរេ ឋិតំ ទេវបុត្តោ សិយាគតោ
តញ្ច អហំ ន ជានាមិ តំ មេ អក្ខាហិ បុច្ឆិតោ

វិមានអ្វីមកនៅពីមុខខ្ញុំ? ប្រហែលជាទេវបុត្រចុះមកទេដឹង?
ខ្ញុំពុំទាន់ស្គាល់អ្នកឡើយ! កាលខ្ញុំសួរអ្នកហើយ សូមអ្នក
ប្រាប់ខ្ញុំកុំខាន! ។

តំ សុត្វា សក្កោ ព្រះឥន្ទ្របានស្តាប់សព្វព្រះរាជឱង្ការពោធិសត្វហើយ ឆ្លើយថា ៖

សក្កោហមស្មិ ទេវិន្ទោ អាគតោ តវ សន្តិកេ
ទានកម្មេន បុញ្ញេន តយ្ហំ ទានានុមោទនេ

*ខ្ញុំឈ្មោះសក្កៈ ជាបមទេវតា មករកព្រះអង្គដើម្បីអនុមោទ-*
*នាត្រេកអរចំពោះទានរបស់ព្រះអង្គ ។*

*ព្រះឥន្ទ្រត្រាស់ព្រះរាជឧក្ការយ៉ាងនេះហើយ ទើបត្រាស់សរសើរ*
*ព្រះពោធិសត្វតទៅទៀតថា ៖*

សព្វេ ជិតា តេ បច្ចយា យេ ទិព្វា យេ ច មានុសា
ព្រហ្មយានមនោកម្មំ សគ្គេ តេ តំ វិបច្ចតុ
តទាសិ យំ ភីសនកំ តទាសិ លោមហំសនំ
មហាទានេ បទិន្នម្ហិ មេទនី សមកម្បថ
និន្នាទិតា តេ បវី សទ្ទោ តេ តិទិវង្គតោ
សមន្តា វិជ្ជុតា អាគូ គិរីនំ វ បតិស្សុតា
តស្ស តេ អនុមោទន្តិ ឧភោ នារទបព្វតា
ឥន្ទោ ព្រហ្មា បជាបតិ សោមោ យមោ វេស្សវណោ
សព្វេ ទេវានុមោទន្តិ ទុក្ករំ ហិ ករោតិ សោ
ទុទ្ទទំ ទទមានានំ ទុក្ករំ កម្មកុព្វតំ

អសន្តោ នានុកុព្វន្តិ   សតំ ធម្មោ ទុរន្វយោ
តស្មា សតញ្ច អសតញ្ច នានា ហោតិ ឥតោ គតិ
អសន្តោ និរយំ យន្តិ   សន្តោ សគ្គបរាយណោ

សត្វនោះបីជាទេវតាក្តី ជាមនុស្សក្តី ព្រះអង្គបានឈ្នះសព្វគ្រប់អស់ហើយ មនោគម្ភដែលជាយានដ៏ប្រសើរ ចូរសម្រេចផលដល់ព្រះអង្គគង់ឋានសួគ៌ចុះ ។ មហាទានដែលព្រះអង្គឲ្យហើយ ធ្វើឲ្យកើតសេចក្តីភិតភ័យផ្អើលភ្ញាក់ព្រឹ-ពេមព្រៃស្បែក ធ្វើឲ្យផែនដីញាប់ញ័រខ្ទរខ្ទារ មហាប្រឹថពីកក្រើករំពើកពុស្ទូរសំឡេងដល់ឋានសួគ៌ ផ្គរបន្ទោរសន្ធោសន្ធៅព្រោលផ្លោតគ្រប់ទិសទីគ្រប់ដំបន់ ក្វឹរន្ទាលផាលប្រវត់ព័ទ្ធភ្នំទាំងឡាយ នារទេពធិតទាំង៤សឹងត្រេកអររីករាយចំពោះព្រះអង្គ, ព្រះឥន្ទ្រ ព្រះព្រហ្ម ព្រះបជាបតី ព្រះចន្ទ្រ ព្រះយមរាជនឹងស្តេចវេស្សវ័ណ ព្រមទាំងទេវតាទាំងឡាយ សុទ្ធសឹងរីករាយអនុមោទនាគ្រប់ៗគ្នា, ព្រោះព្រះអង្គបានធ្វើអំពើដ៏កម្រ; ពួកសប្បុរសរមែងឲ្យរបស់ដែលគេឲ្យដោយកម្រ រមែងធ្វើអំពើដែលគេធ្វើដោយកម្រ ពួកអសប្បុរសធ្វើតាមមិនបាន ព្រោះធម៌របស់សប្បុរស ពួកអសប្បុរសប្រព្រឹត្តតាមបានដោយកម្រ ហេតុនោះ គតិ

របស់ពួកសប្បុរសនឹងពួកអសប្បុរស  រមែងផ្សេងគ្នាតាំងពីកន្លងលោកនេះទៅ  គឺពួកអសប្បុរសទៅកាន់នរក  ពួកសប្បុរសទៅកាន់ឋានសួគ៌ ។

លុះព្រះឥន្ទ្រទទួលអនុមោទនាយ៉ាងនេះហើយ  ក៏ទូន្មានព្រះមហាសត្វថា "បពិត្រមហារាជ!  តាំងពីថ្ងៃនេះទៅ  សូមព្រះអង្គធ្វើបុណ្យឲ្យទានកុំមានសេចក្ដីធ្វេសប្រហែសឡើយ" ។  សម្ដេចសក្កទេវរាជពោលពាក្យក្រើនរំឭកដល់ព្រះមហាសត្វប៉ុណ្ណោះហើយ  ក៏ស្ដេចទៅកាន់ទេវលោកវិញហោង ។

តមត្ថំ បកាសេន្តោ សត្ថា អាហ សម្ដេចព្រះសព្វជ្ញបរមសាស្ដា  ទ្រង់ប្រកាសសេចក្ដីនោះ  ទ្រង់ត្រាស់ដូច្នេះថា៖

ឥទំ វត្វាន មឃវា  ទេវរាជា សុជម្បតិ
បគ្គុរញ្ញោវាទំ ទត្វា  សគ្គកាយំ អបក្កមិ

សម្ដេចមឃវៈ  ជាព្រះស្វាមីនៃនាងសុជាតា  ទ្រង់ប្រទានឱវាទដល់ព្រះបាទចន្ទរាជហើយ  ក៏ស្ដេចត្រឡប់ទៅកាន់ទេវលោកវិញ ។

តាំងពីកាលនោះមក  ព្រះពោធិសត្វមិនដែលប្រហែសធ្វេសក្នុងការបុណ្យឡើយ,  ទ្រង់សោយរាជសម្បត្តិមានទេព្ដារក្សាឥតមានរោគាព្យាធិមកយាយីបៀតបៀន  ទ្រង់ធ្វើបុណ្យឲ្យទានជាដើម  ដរាបដល់អស់

ព្រះជន្មាយុសោយព្រះទិវង្គតរលត់សង្ខារ បានទៅកើតក្នុងឋានសួគ៌ជាន់តុសិតបិតក្នុងវិមានមាសកំពស់ ១២ យោជន៍ មានពពួកស្រីអប្សរបវរកញ្ញាហោមរោមជាបរិវារ ។

សម្តេចព្រះបរមសាស្តា ទ្រង់ប្រកាសនូវសេចក្តីនោះឲ្យជាក់ច្បាស់ ទើបទ្រង់ត្រាស់ថា៖

តតោ បន្ធនាធិបោ ទានំ ទត្វាន ខត្តិយោ
កាយស្ស ភេទា សប្បញ្ញោ សគ្គំ សោ ឧបបជ្ជិត

កាលនោះ ព្រះបាទចន្ទរាជ ជាអធិបតីនៃនរជនទ្រង់ធ្វើទានហើយ ព្រះមហាក្សត្រទ្រង់ប្រកបដោយព្រះប្រាជ្ញា លុះបែកកាយទំលាយខន្ធហើយ ស្តេចក៏ឡើងទៅកើតនាឋានសួគ៌ទេវលោក ។

សម្តេចព្រះបរមសាស្តា ទ្រង់នាំចន្ទរាជជាតកនេះមកហើយ ទ្រង់ត្រាស់ថា "ម្នាលភិក្ខុទាំងឡាយ! តថាគតមិនមែនទើបតែនឹងដោះលែងសត្វទាំងឡាយក្នុងកាលឥឡូវនេះឡើយ, កាលពីដើមដែលតថាគតនៅជាពោធិសត្វកំពុងបំពេញបារមី ក៏ធ្លាប់ដោះលែងសត្វដូច្នេះដែរ" ទ្រង់មានព្រះពុទ្ធដីកាយ៉ាងនេះហើយ ទើបទ្រង់ត្រាស់ប្រកាសសច្ចធម៌ទាំង ៤ ប្រការ, កាលចប់សច្ចធម៌ ភិក្ខុគ្រប់រូបដែលបានស្តាប់ធម៌ទេសនា

សឹងបានសម្រេចគុណវិសេសមានសោតាបត្តិផលជាដើម តាមឧបនិស្ស័យវាសនារៀងៗខ្លួន ។

សម្ដេចព្រះបរមសាស្ដា ទ្រង់ប្រជុំជាតកត្រាស់នូវគាថាខាងចុងនេះដូច្នេះថា ៖

មណិមេខលា ទេវធីតា ឧប្បលវណ្ណា ច ថេរិកា
តទា សោ សីលសម្បន្នោ សារីបុត្តោ តទាគិបិ
តទា មហិលកុមារោ រាហុលោ មម ឱរសោ
សិម្ពលី នាម សា ទេវី រាហុលមាតា យសោធរា
រាជមាតា ច សា នារី មហាមាយា តទាគិបិ
ធនកោ នាម វាណិជោ បិតា សុទ្ធោទនោ អហុ
ជម្ពូទីបេ ច រាជានោ អហេសុំ ពុទ្ធបរិសា
បន្នរាជា នរាធិបោ លោកនាថោ វ សព្វញ្ញូ
ភវន្តោ សាធវោ តុម្ហេ ឯវំ ធារេថ ជាតកំ

នាងទេវធីតាឈ្មោះមណិមេខលា បានមកកើតជានាងឧប្បលវណ្ណាថេរី, ព្រះថេរៈដ៏មានសីលបរិបូណ៌ពីកាលនោះ ឥឡូវនេះបានមកកើតជាភិក្ខុឈ្មោះ សារីបុត្ត, មហិលកុមារក្នុងកាលនោះ ឥឡូវនេះបានមកកើតជារាហុលកុមារជាឱរស

របស់តថាគត, នាងសិម្ពលីទេវី បានមកកើតជានាងយសោ-
ធរាជាមាតានៃរាហុល, ឯព្រះវររាជជននី ឥឡូវនេះបានមក
កើតជាព្រះនាងមហាមាយា, នាយពាណិជឈ្មោះធនកៈ
បានមកកើតជាព្រះវរបិតា ព្រះនាមសុទ្ធោទនៈ, ពួកក្សត្រ
កុរ៍ជម្ពូទ្វីប បានមកជាពួកពុទ្ធបរិស័ទ, ឯព្រះបាទចន្ទកជា
អធិបតីលើជនកុរ៍កាលនោះ គឺអង្គតថាគត ជាសព្វញ្ញពុទ្ធ
ជាទីពឹងនៃសត្វលោកនេះឯង; អ្នកទាំងឡាយជាសប្បុរស
ដ៏ចំរើន ចូរចងចាំទុកនូវជាតកនេះ យ៉ាងនេះចុះ ។

ចប់ចន្ទរាជជាតក ទី ៨ តែប៉ុណ្ណេះ

---

**ទោសនៃការគប់មិត្តអាក្រក់**

សាធុជនធ្លាក់ខ្លួនទៅជាអ្នកមិនមានចិត្តប្រសើរ
ព្រោះទោសនៃការសេពគប់អសប្បុរស, ចូរមើល
ពីស្មៈ ត្រឡប់ទៅជាចោរលួចគោ ព្រោះតែការ
សេពគប់ទុយោធន៍ ព្រោះហេតុនោះ សប្បុរស
លោកវៀរចាកការសេពគប់បុគ្គលថោកទាប ។

បញ្ញត្រ្តៈ

# រឿងសៅរ៍សោយ

(សិសោរជាតក)


## ព្រះមហាឧត្តមវិជ្ជា ផលញាណោ ប៊ុង-ប៉ម

អាចារ្យសាលាបាលីរងវត្តបទុមវតី ក្រុងភ្នំពេញ


រៀបរៀងតាមគម្រាយសាស្ត្រាស្លឹករឹត

( តមក )

---

ពិទូរ្យស្បូរ្យតាន សង្ហារពេជ្រពាន ច្រើនគ្រែអន័គ្ឃ
អនេកគណនា ត្រៀបត្រាឥតអាក់ នាំចូលគគាក់
កុញ្ញកកមហិមា ។ មាសពេជ្រទាំងឡាយ ត្បូងរ័តន៍ឆើតឆាយ
ដែលដាំនៅទា. សង្ហារប៉ុមកុដ ពិសុទ្ធថ្លៃថ្លា
គ្រាន់តែប៉ះគ្នា ជ្រះជ្រោយដោយដី ។ ថ្វាយហើយទិត្យនៅ
បំរើគាល់ហ្វៅ ព្រះបាទបក្រើ ខុះទៅខុះមក
សព្វថ្ងៃប្រក្រតី ខុបខ្ជាបបារមី នរបតីមហិមា ។
រីអស់អ្នកផ្ដាំ អម្បាលដែលចាំ ពដវាំងក្សត្រា
បបួលគ្នារើស មាសពេជ្រនោះណា ១ ថ្ងៃបានជា
៧ នាឡិម្នាក់ ។ សីងតែត្រកអរ ក្នុងចិត្តសាទរ
និយាយពកទាក់ រើសយកសឹងត្បូង កែវកងមាសប្រាក់
ពុំហ៊ានលួចលាក់ នាំយកទៅថ្វាយ ។ រីឯព្រះបាទ
សិសៅរ៍នរនាថ ក្សត្រថ្ងៃពណ្ណរាយ ព្រះអង្គពុំយក

ឲ្យមកបែកបាយ　អស់អ្នកទាំងឡាយ　នោះវិញទីទៃ ។
ឯមហាក្សត្រា　ស្តេចមានអស្សពាហន៍　សេះអាជានេយ្យ
ជាព្រះទីនាំង　សម្រាប់ក្សត្រថ្វៃ　ទាំងពីរប្រពៃ
កំឡាំងស្ទើខ្យល់ ។　មួយនោះឈ្មោះថា　គិបក.អស្សពាហន៍
មួយទៀតថ្កើងថ្កល់　ឈ្មោះមហាលទ:　ឫទ្ធិស័ក្តិសោតសល់
ក្សត្រថ្វៃនិរមល　សព្វព្រះហឫទ័យ ។　បើទ្រង់បង់ទៅ
ប្រពាតលេងនៅ　ពិភពនាគនៃ　ស្តេចក៏ឡើងគង់
គិបកមះនោម័យ　ដែកដីទៅវៃ　ដល់ដូចចិន្តា ។
ស្តេចទតសព្វសាយ　ពិភពនាគនាយ　សប្បាយមហិមា
ស្រេចហើយមហាក្សត្រ　ចក្រពត្តិពជា　ឡើងគង់អស្សពាហន៍
ដែកដីលឿនក្រៃ ។　ហួសមកដល់អាយ　ក្សត្រថ្វៃពណ្ណកាយ
ទឹកក្នុងហឫទ័យ　បង់ទៅប្រពាត　ហេមពាន្តនាយនៃ
ស្តេចបរមនោម័យ　ដល់ព្រៃហេមពាន្ត ។　ដល់ស្រេចពុំលង់
ក្សត្រថ្វៃវរវង្ស　ទ្រង់ទតកំសាន្ត　ក្រសាលព្រះទ័យ
ក្នុងព្រៃហេមពាន្ត　ថ្នាក់ថ្នល់ទិហាន　ទើបបានដល់ស្រះ ។
រីស្រះនោះណា　មានទឹកជ្រៅថ្លា　ត្រចង់ត្រចះ
ធេងធំទូលាយ　សប្បាយពេកណាស់　រឯនាមស្រះ
ឈ្មោះអនោតត្ត ។　ក្សណនោះព្រះបាទ　សិរសៅរ៍នាថ

ក្សត្រថ្ងៃវរវ័តន៍ ផ្កាសំពរពស្តា លីលាចុះថ្លាក់
ស្រង់ស្រោចបំបាត់ ទុក្ខក្នុងអង្គប្រាណ ។ មើលមានឈូកប្រាល
ផ្កាវីករន្ទាល ដេរដាសពាសបាន ប្រើនក្រៃប្រាកដ
កំណត់មែនមាន ពីនោះទៅបាន ដល់ឈូកសសល់ ។
ពីនោះទៅទៀត សុទ្ធសឹងត្រកៀត កញ្ឆែតទុត្យល
មែនមានថ្ងៃថ្វា ត្រៀបត្រារបល់ ពីនោះទៅដល់
សុទ្ធសឹងក្រចាប់ ។ ព្រលឹតលំចង់ ផ្កាវីកត្រយង់
កន្ទង់ហើរហាប់ ក្រេបកេសរផ្កា អ៊ូអាអឺងអាប់
ទំដោយស្រទាប់ ជញ្ជាបកេសរ ។ ក្សត្រថ្ងៃប្រសើរ
ស្ដេចទតមៀងមើល បុប្ផាបវរ សប្បាយហ្ញទ័យ
ក្នុងស្រះបោក្ខរ ស្រេចហើយស្ដេចបរ ឡើងពីគង្គា ។
ស្ដេចឡើងមនោម័យ ក្សិណក្សត្រដៀសជ័យ បើកបរលីលា
វិសេះតិបក: កម្លាំងមហិមា នាំអង្គក្សត្រា
ដល់កំពង់ថ្ងៃនោះ ។ ទើបស្ដេចយាត្រា ចុះពាក្យអស្សពាហន៍
ហើយទ្រង់យាងផ្ដោះ ឡើងលើប្រាសាទ សីហនាទឥតខ្ចោះ
សុខសាន្តស្ងាតស្ងោះ ក្នុងព្រះទយា ។ បើព្រះសិសៅរ៍
ស្ដេចនឹកចង់ទៅ ទតស្ថានសួគ៌ា ស្ដេចយកអាជានេយ្យ
ប្រពៃនាមា មហាលទ:អស្សពាហន៍ ជិះបោះប្រៀវប្រែ ។

ព្រះអង្គមហាក្សត្រ ទៀនទតសម្បត្តិ ស្ពានសួគ៌នោះនៃ
មើលប្រាសាទមាស ឧកាសភ្លឺក្រៃ រុងរឿងប្រពៃ
រន្ទាលព្រាលផ្អៅ ៗ ស្ដែងស្ដេចទតទៀង ព្រះនេត្រាឆៀង
រៀងៗទៀតទៅ យល់ប្រាសាទប្រាក់ ដោយថ្នាក់ជាន់នៅ
ភ្លឺផ្លេកសន្ធៅ ព្រោងព្រាយពេកក្រៃ ៗ កែវកងប្រាក់មាស
ដេរដាសពេញពាស ព្រៃព្រំថ្ងាថ្ងៃ សុទ្ធសឹងល្អល្អះ
ស្អេកស្កះក្រាស់ក្រៃ មើលមានខៀនស្បៃ ជម្ពូទេសទុំ ៗ
ស្ដេចទតស្រីសួគ៌ ប្រសើរគាប់គួរ សុទ្ធសឹងក្រមុំ
ល្អល្អះល្ពេញល្ពៅ ស្រដៅកុះកុំ ដោយពួកដោយក្រុម
ពេញព្រហ្មចារី ៗ ត្របង់ត្រចះ ស្រលូតស្រឡះ
ស្រអាតប្រិមប្រិយ ទ្រមើទ្រមម ស្រទន់ស្រស់ស្រី
ស្រស់ស្រិលពិសី ទ្រទេសទងវង ៗ ល្ហាសល្ហន់កាយា
គន់ទៅកត្រា ផូរផង់បំព្រង ដូចចន្ទបូណ៌មី
ស្រស់ស្រីឥតហ្មង មើលមិនមានឆ្គង គួរឲ្យស្នេហា ៗ
ព្រះបាទក្សេមក្សាន្ត ស្ដេចទតសួគ៌ស្ថាន មហារាជិកា
ហើយហួសទៅឮ ស្ថានត្រៃត្រិង្សា ឡើងទៅយាមា
តុសិតសួគ៌ទាយ ៗ ស្ដេចទតសព្វគ្រប់ ប្រាំមួយជណ្ដប់
ស្ថានសួគ៌តណ្ណាកាយ សប្បាយហ្ឫទ័យ ក្សត្រថ្លៃធោមធាយ

ក្រេមក្សាន្តសប្បាយ ឥតឯគណនា ។ ស្រេចហើយព្រះអង្គ
ក្សត្រក្សាន្តវរវង្ស ស្ដេចវិលលីលា សេះនាំហោះមក
ចុះចាកសួគ៌ា ដល់នគរ នៅនាថ្ងៃនោះ ។
អស់មុខមន្ត្រី សេនាសេនីយ ទង់គាល់ចំពោះ
អករ៍យាយស្រីង្គា ក្រមុំកំឡោះ គង់គាល់ស្មានស្មោះ
ជាប់ជាប្រក្រតី ។ មានទាំងមហោស្រព ទាំងថ្ងៃទាំងយប់
ស័ព្ទសូរដន្ទ្រី ឮលាន់រណ្ដំ សេពសមខ្លុយប៉ី
ត្រែស័ង្ខវែងខ្លី រនាតពាតគង ។ ព្រះបាទសិសោរ៍
ស្ដែងស្ដេចគង់នៅ សោយរាជ្យគ្រប់គ្រង សុខសាន្តប្រក្រតី
ឥតបីមានហ្មង ថ្កើងយសកន្ទង លែងស្ដេចនានា ។
ស្ដេចទ្រង់ទសពិធ រាជធម៌ដោយក្រិត្យ ពុំមានឃ្លាតឃ្លា
រក្សាសីល ៥ សីល ៨ ណា ព្រះទ័យសទ្ធា
ធ្វើបុណ្យឲ្យទាន ។ ចែកចាយអស់ទ្រព្យ គ្រប់គ្រឿងប្រដាប់
សម្រាប់មែនមាន ឯសូមយាចក ទុគ៌តអត់ឃ្លាន
តែងចូលយកទាន សព្វថ្ងៃប្រក្រតី ។ ស្ដេចតែងសង្វាត
ប្រតិបត្តិពុំឃ្លាត សព្វសីល ៨ តាមដោយទម្លាប់
ពីបុកណខ្ញី ដូចជាពោធិ — សត្វព្រៃនាយណក ។
ព្រះចៅមហាក្សត្រ សោយរាជ្យសម្បត្តិ សុខសាន្តមហិមា

ពស្ដាសសម្បុរ　ហៀរហូរគោគា　ហោរខ្ទយក្ដីណា
ពុំមានឡើយហោង ៗ

　មានកាល ១ ថ្ងៃ　ពត្រីសម័យ　ក្សត្រថ្ងៃច្បាស់ច្បង
ចរចូលបន្ទំ　មនោរម្យឥតហ្មង　លង់លក់ជាម្ដង
ពត្រីនោះណា ៗ　ស្ដេចទ្រង់យល់សប្ដ　និមិត្តជាអព -
មង្គលមហិមា　ដូចជាកំពូល　ប្រាសាទថ្ងៃថ្លា
បាក់បែកពីគ្នា　ធ្លាក់ចុះដល់ដី ៗ　ទើបព្រះពជា
តើនបាកនិទ្រា　កណ្ដាលពត្រី　គន់គិតរំពឹង
រឹងភ័យអស់ក្ដី　ព្រួយណាស់បក្រី　គ្រៀមក្រំក្រៃ ៗ
ព្រះអង្គគន់គិត　ដ្បិតយល់និមិត្ត　ហាក់ប្លែកប្លែះណា
រន្ធត់អស់អង្គ　ស្រយង់កាយា　ព្រួយព្រះចិន្ដា
កន្លងពត្រីយប់ ៗ　លុះព្រឹកព្រានព្រះ　សុរិយារះរៀង
ព្រះអង្គគិតថប់　ចុះបាកសយនា　ក្សត្រាសញ្ជប់
ថប់ហើយរឹងថប់　ផ្កាៗមមៃ ៗ　ស្ដេចទ្រង់ចិន្ដា
គិតគ្រប់ថប់ថា　ឧសប្ដនេះនៃ　នឹងកើតជាហេតុ
គេទុកាក្រក់ក្រៃ　វិបរិតបន្ថែ　ដល់អញដឹងពា ៗ
ប្ដីមួយនឹងទៅ　ត្រូវនាងស្រីពៅ　ភរិយាអញណា
ប៉ុន្តឹងអន្ដរាយ　ដល់នគរ　ឬពស្ដ្របជា -

មាត្យមុខមន្ត្រី ៗ បានជាប្រាសាទ ប្រសើរស្អាងស្អាត
បាក់ធ្លាក់ដល់ដី ឬមានកលិយុគ កើតទុក្ខអ៊ូៗ
ឬដល់ក្ស័យដី - រិតម្តេចទៅអើយ ៗ ព្រះអង្គរឹងថប់
គិតដៅទៅគ្រប់ ឥតឯមានស្បើយ ក្នុងព្រះហ្ឫទ័យ
ក្សត្រថ្ងៃត្រាណត្រើយ ផ្អកផ្អៀងកេសកើយ សញ្ចប់ក្ត្រា ៗ
ពេលនោះឯងហោង វិបល្លាស ៥ ភង កើតដល់ពជា
១ គឺកូលក្តៅ ហ្មងសៅចិន្តា ២ គឺកាយា
មានញើសហូរខ្លាយ ៗ ៣ គឺកាយា សៅហ្មងវណ្ណា
៤ គឺព្រះកាយ រន្ធត់ស្មោរស្មប់ ចំប្រប់សព្វសាយ
៥ គឺប្រែក្លាយ ងងឹតនេត្រា ៗ ព្រះបាទចមកត
តក់ស្លុតចំប្រប់ សាយសព្វរោមា រំជួលអស់អង្គ
ស្រយង់កាយា ត្រាស់ប្រើអមច្ចា ទៅហៅគ្រូទាយ ៗ
ក្សណនោះអមច្ចា បង្គំវន្ទា ក្សត្រាពណ្ណរាយ
រូតរត់ដល់ទៅ លំនៅហោរនាយ ស្រែកប្រាប់ពីឆ្ងាយ
ផ្សិតប្រើប្រញាប់ ៗ ថាហៃហោរ ស្តេចមានបញ្ជា
"ឲ្យទៅឆាប់ៗ កុំបង្អង់នៅ ចូលទៅប្រញាប់"
ហោរាស្តេងស្តាប់ ចាប់យកដំរា ៗ ដីសក្តារធន
ប្រុងប្រៀបរៀបខ្លួន ស្រេចហើយយាត្រា រូតរត់មកដល់
មណ្ឌលប្រាង្គប្រា - សាទហើយម្ពីម្ពា ក្រាបថ្វាយបង្គំ ៗ (មានត)

# រឿងសាមកុក

## ឧកញ៉ាវិបុលរាជសេនា នូ-កន ប្រែរៀបរៀង

(តមក)

---

រឿងសាមកុកទុកជាយុទ្ធសាស្ត្រ
អ្នកវាងវៃឆ្លាសបើបានអាន
នឹងបេះឧបាយកលបំណាន
ទាំងមានសន្តានស្នេហាជាតិ ។

### កណ្ឌទី ១៩

តាំងពីឡេវពីនឹងតាំងស៊ុនរួមគំនិតគ្នានឹងសម្លាប់ចូឆូ រហូតដល់គួនអ៊ូសម្លាប់គី-មៅ, តៀវហ៊ុយសម្លាប់គ្រប់គ្រួគី-មៅ ឡេវពីមានសេចក្តីព្រួយខ្លាចចូឆូ ។

---

ឡេវពីទទួលពាក្យតាំងស៊ុនហើយកាលណា នឹងធ្វើការអ្វី ៗ ក៏ឲ្យគិតខ្លាចចូឆូនឹងមិនទុកចិត្ត ទើបក្លែងធ្វើបន្ទាយខ្លួនយកឈើមកប្រុះធ្វើជាសម្រាសរបងដាំស្លួនច្បារបន្លែបង្ការគ្រប់មុខរៀងរាល់ថ្ងៃ ។ គួនអ៊ូ, តៀវហ៊ុយនិយាយនឹងឡេវពីថា ការណ៍ដែលត្រូវគិត ម្តេចមិនរិះគិត? បងមកធ្វើដូចជាមនុស្សថោកទាបដូច្នេះមិនគួរសោះ ដែលបងធ្វើដូច្នេះតើជាប្រយោជន៍អ្វី? ។ ឡេវពីតបថា ប្អូនទាំង ២ មិនបានដឹងដល់គំនិតដែលបងគិតនោះទេ កុំមកស្តីបន្ទោសឲ្យរវល់ចិត្តគំនិតឡើយ ។ គួនអ៊ូ, តៀវហ៊ុយ ក៏ឈប់ស្ងៀម ។

ថ្ងៃមួយនោះ មានមនុស្សនាំរឿងទៅនិយាយប្រាប់ចូចូថា ទ្បៀតីធ្វើចម្ការដាំច្បារសួនខ្លួនឯងសព្វ ៗ ថ្ងៃ ៗ ចូចូក៏ប្រើទៅធូនឹងតៀវលៀវ ហើយនឹងទាហានចំនួន ២០ នាក់ទៅអញ្ជើញទ្បៀតី ៗ ទៅធូ, តៀវលៀវចូលទៅក្នុងផ្ទះទ្បៀតី មិនឃើញគួនអ៊ូតៀវហ៊ុយ ឃើញតែទ្បៀតីកំពុងដាំបន្លែក្នុងច្បារសួន ក៏ចូលទៅជំពបទ្បៀតីថា មហាឧបរាជឲ្យខ្ញុំមកអញ្ជើញលោកទៅ ៗ ទ្បៀតីក៏ភ័យស្លុតក្នុងចិត្តក៏សាកសួរថា មហាឧបរាជឲ្យមកហៅខ្ញុំដោយមានការអ្វី? ៗ ទៅធូថា មានការអ្វីខ្ញុំបាទក៏ពុំអាចដឹង ៗ ទ្បៀតីមិនហានខានក៏រៀបខ្លួនទៅជាមួយនឹងទៅធូ, តៀវលៀវ ៗ ចូចូឃើញទ្បៀតីទៅដល់ក៏ចំអនថា អ្នកនៅផ្ទះសព្វថ្ងៃនេះធ្វើការធំមាំមួនណាស់ ៗ ទ្បៀតីឮចូចូថាដូច្នោះ នឹកស្មានក្រែងចូចូដឹងសេចក្តីក៏ភ័យស្លុតក្នុងចិត្តស្ងៀមនៅ មិនឆ្លើយតបថាដូចម្តេចសោះ ៗ ចូចូក៏ចាប់ដឹកដៃទ្បៀតីនាំចុះទៅក្នុងសួនច្បារខាងក្រោយផ្ទះ ហើយនិយាយថា អ្នកនៅផ្ទះរិះគិតធ្វើសួនដំណាំដាំបន្លែបង្ការ ប្រហែលសួនច្បាររបស់យើងដែរឬ? ៗ ទ្បៀតីយល់ថា ចូចូមិនមែនដឹងដល់ក៏ធូរស្រាលក្នុងចិត្តឆ្លើយតបថា ខ្ញុំបាទមកទីពឹងជ្រកកោនបុណ្យលោកសព្វថ្ងៃនេះមិនមានការអ្វីនឹងធ្វើឲ្យពេញកំឡាំង បានជាធ្វើសួនច្បារកែអផ្សុក តែនឹងបានធ្វើឲ្យពេញមុខដូចសួនច្បាររបស់លោកក៏ទេ ៗ

ចូចូអង្គុយនិយាយលេងជាមួយនឹងទ្បៀតី ក៏ក្រឡេកឃើញផ្លែ-កន្ទួត ១ ដើមក៏ចង្អុលឲ្យទ្បៀតីមើលហើយថា កាលយើងទៅច្បាំងនឹង

តៀវស៊ីវ ទាហានទាំងពួងស្រេកទឹកណាស់ យើងក៏គិតកលឧបាយបញ្ឆោតថា ឲ្យខំស្វាហាប់ដើរបន្តិចទៅទៀតចុះ នឹងបានជួបប្រទះព្រៃកន្ទួតផ្លែច្រើនណាស់នៅឯមុខ ទាហានទាំងអស់បានឮបញ្ចេញឈ្មោះផ្លែកន្ទួតជាម្ជូរ ក៏ហូរបញ្ចេញទឹកមាត់គ្រប់ៗគ្នា ណាដែលស្រេកទឹកនោះក៏អន់ស្រេកទៅវិញ ។

ឡៅពីសរសើរប្អូនថា ប្រាជ្ញាឈ្លាសវៃនៃលោកនឹងរកនរណាស្មើគ្មាន ។ ប្អូនក៏អញ្ជើញឡៅពីឲ្យអង្គុយលើកៅអីក្នុងទីសួនត្រជាក់ ហើយសេពសុកស៊ីផ្លែកន្ទួតនោះជាកំសាន្តសប្បាយ ។

កាលប្អូននឹងឡៅពីផឹកស្រាស៊ីផ្លែកន្ទួតជាមួយគ្នានោះ ក៏បណ្តាលខ្យល់ក្បុះសង្ឃរាមេឃងងឹតធ្លាក់ភ្លៀងរំលា ទាហានទ័ទឹងមនុស្សម្នាស្រែកថា ម្ករសំដែងរិទ្ធិ៍លើអាកាសបានជាកើតអស្ចារ្យដូច្នេះ ។ ប្អូននឹងឡៅពីបានឮមនុស្សម្នាស្រែកដូច្នោះ ក៏ងើយមើលទៅលើអាកាសឃើញមេឃងងឹតខ្លាំងក៏ដឹងថា ម្ករសំដែងរិទ្ធិ៍ ប្អូនបង់ដឹងប្រាជ្ញាឡៅពីទើបក្លែងសួរថាអ្នកដឹងឬទេ គឺម្ករសំដែងរិទ្ធិ៍បានជាងងឹតដូច្នេះ? ឯរិទ្ធិ៍ម្ករនោះតើមានប៉ុន្មានយ៉ាង? ។ ឡៅពីក្លែងធ្វើជាមិនដឹងថា ម្ករសំដែងរិទ្ធិ៍មានប៉ុន្មានៗ ខ្ញុំបាទមិនអាចដឹងទេ ។ ប្អូនថា ម្ករសំដែងរិទ្ធិ៍នោះ ទំងធ្វើឲ្យធំឲ្យតូចដូចម្តេចក៏បេះតែបាន បើនឹងហោះឡើងទៅលើអាកាស ហើយសំដែងរិទ្ធិ៍ផ្សេងៗ ទោះអាកាសនោះបង្អៀតក្តីទូលាយក្តីក៏អាចធ្វើឲ្យទៅតាមរិទ្ធិ៍បាន

សូម្បីទឹងហោះចុះក្នុងផ្ទៃមហាសមុទ្រ ធ្វើរិទ្ធិឲ្យរូបកាយនោះតូចទៅចូលទៅជ្រកនៅក្រោមបាតក្អំក៏បាន ឯទេសៈកាលៈនេះជារដូវភ្លៀងបានជាម្ករសំដែងរិទ្ធិដូច្នេះ ឧបមាដូចជាមនុស្សមានសតិបញ្ញាជ្រៅទូលាយ បើទឹងធ្វើការក៏គ្រេះគិតតាមសេចក្តីសមគួរ ទោះបីឃើញថាការនោះធំ ក៏ធ្វើឲ្យធំ បើការនោះតូចក៏ប្រមាណការធ្វើឲ្យតូចទៅ សព្វថ្ងៃនេះនរណាខ្លះដែលមានសតិបញ្ញាដូចម្ករសំដែងរិទ្ធិនោះ? ចូរអ្នកអធិប្បាយឲ្យច្បាស់មកចុះ ។ ទៀតពីក្លែងតបថា ខ្ញុំបាទមិនសូវមានបញ្ញាទេ ដែលទឹងបានបុណ្យស័ក្តិជាមន្ត្រីខ្ញុំរាជការប៉ុណ្ណេះ ក៏ព្រោះគុណមហាឧបរាជជួយទូលស្នើឲ្យខ្ញុំបាទក៏បានសេចក្តីសុខរៀងមក ដែលទឹងដឹងថា អ្នកឯណាមានសតិបញ្ញាជ្រៅជ្រះទូលាយដូចម្ករសំដែងរិទ្ធិនោះ ដំរែះខ្ញុំបាទគិតមិនដល់ទេ ។ ចូចូបានឮដូច្នោះក៏ឆ្លើយថា គំនិតទឹងដំរែះប្រាជ្ញារបស់អ្នកមានប្រាកដ ហេតុម្តេចអ្នកក្លែងបរិហាបន្ទាបបន្ថោកខ្លួនដូច្នេះ ទោះបីមិនមានបញ្ញាគិតឲ្យឃើញរហូតទៅបាន ក៏គង់មានឮចាស់បូរាណនិយាយហើយ ទឹងដឹងថា អ្នកនេះអ្នកនោះជាមនុស្សមានសតិខ្ពស់ទៅដែរ ។ ទៀតពីក្លែងថា ខ្ញុំបាទបានទឹកឃើញថា សព្វថ្ងៃនេះអ៊ុនស៊ុតចៅហ្វាយស្រុកឡាំយុំងមានសតិបញ្ញាឆ្លៀវឆ្លាតណាស់ សេនាទាហានធំតូចក៏មានថ្វីដៃខ្លាំងពូកែច្រើន ទាំងស្បៀងអាហារក៏បរិបូណ៌ ។ ចូចូបានឮដូច្នោះក៏អស់សំណើចហើយតបថា អ៊ុនស៊ុតនោះមានឧបមាដូចសត្វនៅក្នុងរណ្តៅ,

ដែលទឹងរាប់ថាមានសតិបញ្ញានោះមិនត្រូវសោះ តែគំនិតមារយាទអ៊ួន-ស៊ុតនោះ ខ្ញុំទឹងចង់យកមកក៏បានដោយងាយណាស់ ៗ

ទៀតពីថា អាណាខែត្រនៅទិសខាងជើងខ្ញុំបានឃើញថា អ៊ួនសៀវចៅហ្វាយស្រុកគីដីវ ជាបងអ៊ួនស៊ុតនោះ ក៏មានពូជជានាហ្មឺនតៗគ្នាមក ៣-៤ ដំណៈហើយ ឥឡូវអ៊ួនសៀវក៏ប្រមូលសេនាទាហានបានច្រើន ទាំងមានទីប្រឹក្សាក៏ច្រើននាក់ ខ្ញុំបាទពិគ្រោះមើលទៅឃើញថាអ៊ួនសៀវមានសតិបញ្ញាមុតមាំធំជ្រៅទូលាយ ៗ បុច្ឆថា អ៊ួនសៀវនោះជាមនុស្សផ្គួតបុណ្យស័ក្តិណាស់ មានតែសេចក្ដីខ្លាច គិតការអ៊ើបង់ច្រើនបានតិច ដែលទឹងរាប់ថាជាមនុស្សមានសតិបញ្ញានោះមិនត្រូវ ៗ ទៀតពីថា ទៀវពៀវចៅហ្វាយស្រុកគេងដីវមានស្រុកធំៗ ឡើងជាបំណុះដល់ ៩ មណ្ឌល ចិត្តថ្លើមក៏ល្អជាមនុស្សស្រួលរាយរាប់អានពួកម៉ាក មានសេនាទាហានក៏ច្រើន ខ្ញុំបាទយល់ឃើញថាជាមនុស្សមានសតិបញ្ញាបានជាធ្វើការឲ្យគេចុះចូលជាច្រើនដូច្នេះ ៗ

បុច្ឆតបថា ទៀវពៀវនោះមានពួកម៉ាកច្រើនក៏មែន តែជាមនុស្សមិនមានសេចក្ដីសត្យសុចរិត បានតែមាត់ផ្អែម ទឹងរាប់ថាជាមនុស្សមានសតិបញ្ញាក៏មិនត្រូវ ៗ ទៀតពីថា ស៊ុនសិកចៅហ្វាយស្រុកកាំងតាំងនោះនៅក្មេងកំឡោះមានកម្លាំងខ្លាំងពូកែសេនាទាហានក៏ច្រើន ខ្ញុំបាទឃើញថាជាមនុស្សមានគំនិតមារយាទមាំមួន ត្រូវទុកជាសេនាម្នាក់មានថ្វីដៃ

ខ្ជាំងពូកែ ។ ចួចថា ស៊ីនសិកនោះមានថ្វីដៃជាប្រមាណ ដោយសារបានទាហានរបស់ស៊ីនគៀនជាបិតាទុកជាកម្លាំងតមក ទើបកំរើបចិត្ត, ដែលទីងកប់ថាជាមនុស្សមានគំនិតគិតល្អ នោះយើងមិនទាន់ឃើញផងទេ ។ ទៀតថា ខាងកាណាវៃ ត្រូវិសឯលិបនោះ ខ្ញុំបានឃើញទៀតជៀងថៅហ្វាយស្រុកសែឈួន មានសតិបញ្ញា ហើយជាពូជព្រះមហាក្សត្រមកអំពីមុន ។

ចួចតបថា ជាពូជព្រះមហាក្សត្រក៏មែន តែជាមនុស្សមិនចេះគិតការអ៊ីសោះ ឧបមាដូចសុនខចាំទ្វារផ្ទះ ដែលទីងកប់ថាជាមនុស្សមានសតិបញ្ញានោះក៏មិនមែន ។

ទៀតទើបសួរថា គៀវស៊ីវ ១, គៀវខ្យ ១, ហាន់ស៊ុយ ១ ទាំង ៣ នាក់នេះលោកយល់ឃើញយ៉ាងម្តេច? ។ ចួចបានឮដូច្នោះក៏ទះដៃអស់សំណើចហើយថា ឯគៀវស៊ីវ, គៀវខ្យ, ហាន់ស៊ុយនោះ ជាមនុស្សមានតែឈ្មោះ នឹងលើកយកសេចក្តីគិតការអ្វីជាប្រាកដគ្មានសោះ អ្នកយកមកនិយាយធ្វើអ្វីឲ្យពេយមាត់ ឯមនុស្សដែលមានសតិបញ្ញានោះ បើនឹងគិតការអ្វីក៏ជ្រៅទូលាយពេះពយកប់អ.នអ្នកទាំងពួង ឧបមាដូចបុគ្គលលេបកែវដ៏ជាទិព្វទុកក្នុងពោះ បើនឹងទៅទីស្ថានឯណា ទោះជាពេលយប់ងងឹតក៏លិចប្រះធ្លុះទៅដោយពន្លឺស្ទើកែវ បើនឹងគិតការអ្វីក៏ដឹងច្បាស់ការធ្ងន់ការស្រាលបាននឹងបង់ ចេះចែករំលែកមិនឲ្យអ្នកឯណាកន្ទង់ដឹងដល់គំនិតប្រាជ្ញា ទើបគេកប់ហៅថាអ្នកមានសតិបញ្ញាជ្រៅទូលាយ ។

ទៀតពីបានស្តាប់ដូច្នោះទើបក្រែងតបថា សព្វថ្ងៃនេះនឹងរកអ្នកឯណាឲ្យមានសតិបញ្ញាដូចមហាឧបាភជថានោះគ្មានសោះ ។ ចូឆ្ចូថា សព្វថ្ងៃនេះយើងសំឡឹងមើលអ្នកមានសតិបញ្ញានោះសូន្យហើយ មានតែខ្លួនអ្នកនឹងខ្ញុំ ២ នាក់ប៉ុណ្ណោះ ។ ទៀតពីព្រួចូឆ្ចូថាដូច្នោះ ក៏ធ្វើជាស្មុគរន្ធត់ចិត្តផ្ទាក់បង្កើះរបូតបេញពីដៃទទួលព្រួសំឡេងរន្ទះផ្គ ទៀតពីក៏ធ្វើភ័យភ្ញាក់យកដៃខ្ទប់ត្រចៀក ។ ចូឆ្ចូឃើញដូច្នោះក៏អស់សំណើចហើយថា កើតមកជាកូនប្រុស ហេតុម្តេចក៏ភ័យខ្លាចនឹងសំឡេងផ្គដូច្នេះ ។ ទៀតពីថា បូរាណជំណាលទុកមកថា បើមានផ្គរន្ទះឲ្យរាំងរក្សាខ្លួនឲ្យណាស់ ។ ចូឆ្ចូមិនបានដឹងកលក៏អស់សង្ស័យ នឹកតែក្នុងចិត្តថា "ទៀតពីជាមនុស្សខ្លាចណាស់ នឹងគិតធ្វើការធំទៅមិនបាន" តាំងពីថ្ងៃនោះតមកចូឆ្ចូក៏មិនមានវេងវៃក្រែងខ្លាចគំនិតប្រាជ្ញាទៀតពី ។

ឯគូនអ៊ូនឹងតៀវហ៊ុយដែលទៅហាត់បាញ់ធ្នូនោះ លុះត្រឡប់មកមិនបានឃើញទៀតពី ក៏សួរមនុស្សក្នុងផ្ទះថា បងយើងទៅណា ? ។ មនុស្សបំរើក៏ប្រាប់ថា ចូឆ្ចូឲ្យមកអញ្ជើញទៅយូរហើយ ។ គូនអ៊ូ, តៀវហ៊ុយព្រួថាដូច្នោះ ក៏ភ័យស្មុគស្មារតីទម្លាក់ធ្នូបោលចាប់យកក្រប៊ី រវៀសរវៃទៅតាមទៀតពី លុះទៅដល់ទ្វារផ្ទះចូឆ្ចូ អ្នកចាំទ្វារឃាត់មិនឲ្យចូល គូនអ៊ូ, តៀវហ៊ុយក៏មិនស្តាប់ដើរចូលទៅក្នុងផ្ទះចូឆ្ចូ ដឹងថាចូឆ្ចូនាំទៀតពីទៅអង្គុយក្នុងសួនច្បារ គូនអ៊ូ, តៀវហ៊ុយក៏តាមទៅ ។ ឯចូឆ្ចូកំពុងអង្គុយផឹកស្រា

ជាមួយនឹងឡៅពីក្រឡេកឃើញគួនអ៊ូ, តៀវហ៊ុយកាន់ក្រប៊ីដើរចូលមក ក៏សួរថា អ្នកទាំង ២ កាន់ក្រប៊ីដើរចូលមកធ្វើអ្វី? ។ គួនអ៊ូ, តៀវហ៊ុយឆ្លើយថា ខ្ញុំបាទដឹងថាមហាឲៈពកដហៅឡៅពីមកបរិភោគលៀងនៅទីនេះ បានជាខ្ញុំបាទមករាំក្រប៊ីជូនឲ្យលោកមើលកំសាន្ត ។

ប៉ូឆូថា អ្នកឯងមកធ្វើដូច្នេះ ដូចមានរឿងក្នុងបុគហាយកត់ហេតុបុរាណកាល គ្រាព្រះចៅឈប៉ាអង គិតប្រទូសរ៉ាយព្រះចៅឡៅប៉ាំង ព្រះចៅឈប៉ាអងអញ្ជើញព្រះចៅឡៅប៉ាំងទៅសោយក្រយាស្ងោយ ហើយគិតកល់ៗបាយឲ្យហាន់ដួងចេញរាំក្រប៊ី បំណងនឹងប្រទូសរ៉ាយព្រះចៅឡៅប៉ាំង ហួនគុយប្អូនថ្លៃព្រះចៅឡៅប៉ាំង ឃើញហាន់ដួងរាំក្រប៊ីចូលមកជិតក៏មិនទុកចិត្ត ទើបនិយាយថា "ឯក្មេងក្រប៊ីនោះ នឹងរាំតែម្នាក់ឯងមិនល្អមើលទេ យើងនឹងចេញរាំទល់ទើបល្អ" ហើយហួនគុយក៏ហូតក្រប៊ីក្រោកឡើងរាំផង ហាន់ដួងលើកក្រប៊ីឡើងនឹងកាប់ព្រះចៅឡៅប៉ាំង ហួនគុយក៏យកក្រប៊ីរងជាប់ បានជាព្រះចៅឡៅប៉ាំងមិនមានសេចក្តីអន្តរាយ; ឯខ្ញុំយើងគ្រានេះ នឹងបានគិតប្រទូសរ៉ាយឡៅពីឲ្យដូចព្រះចៅឈប៉ាអងគិតប៉ងនឹងប្រទូសរ៉ាយព្រះចៅឡៅប៉ាំងដូច្នោះក៏ទេ ដែលអ្នកនឹងមកធ្វើដូច្នេះមិនគួរ ។

គួនអ៊ូ, តៀវហ៊ុយឆ្លើយថា ខ្ញុំបាទមិនមែនគិតធ្វើដូច្នោះទេ បើលោកនៅសង្ស័យហើយខ្ញុំបាទក៏មិនរាំ ។ ប៉ូឆូក៏ប្រើមនុស្សបំរើមនុស្សចាក់ស្រា

ឲ្យគួនអ៊ូ, តៀវហ៊ុយផឹក ៗ លុះពេលរសៀល ឡេវពី, គួនអ៊ូ, តៀវហ៊ុយ ក៏គំនាប់លាបូឆូនាំគ្នាត្រឡប់ទៅផ្ទះវិញ ៗ គួនអ៊ូនិយាយនឹងឡេវពីថា ខ្ញុំត្រឡប់មកពីហាត់បាញ់ធ្នូដឹងថា បូឆូឲ្យហៅលោកទៅ ខ្ញុំបាទភ័យណាស់ គិតសង្ស័យថា បូឆូនឹងធ្វើលោកយ៉ាងម្ដេចមិនដឹង ទើបនាំគ្នាស្រូតទៅតាមលោក ៗ ឡេវពីក៏អធិប្បាយរាយរឿងឲ្យគួនអ៊ូ, តៀវហ៊ុយស្ដាប់គ្រប់ប្រការថា បូឆូនាំទៅផឹកស្រាស៊ីផ្លែកន្ទួតក្នុងសួន ៗ គួនអ៊ូថា ដែលបូឆូធ្វើដូច្នេះ បងនឹងយល់ឃើញដូចម្ដេចខ្លះ? ៗ ឡេវពីថា បងគិតធ្វើសួនច្បារដាំបន្លែបង្ការ ព្រោះថាដើម្បីនឹងឲ្យបូឆូអស់សេចក្ដីសន្ទុះសង្ស័យថា យើងផុតសេចក្ដីរិះគិតការអ្វីហើយ កាលបូឆូបបួលស៊ីលៀងនិយាយសរសើរថា បងមានដំរេះប្រាជ្ញ ទទួលឮសំឡេងផ្គររន្ទះបងធ្វើហាក់ជាភ្ញាក់ធ្លាក់ចង្កឹះពីដៃ ហើយយកដៃខ្ទប់ត្រចៀក បូឆូក៏អស់សេចក្ដីសង្ស័យ ៗ គួនអ៊ូ តៀវហ៊ុយថា បងរិះគិតធ្វើឧបាយដូច្នេះល្អណាស់ ៗ

(មានត)

# នាលៈ និង ទមយន្តី

## រឿងព្រេងប្រទេសឥណ្ឌា

## អ្នកស្រីត្រឹង-សារិយ៉ាន់ ក្រុមពុទ្ធសាសនបណ្ឌិត្យ ភ្នំពេញ

ប្រែពីភាសាបារាំងមកជាភាសាខ្មែរ

(តមក)

---

ព្រះអង្គម្ចាស់បុស្ការៈ មានបន្ទូលនឹង កាលី ថាៈ "ព្រះឥន្ទ្រាធិរាជនៅថែរក្សាព្រះបាទនាលៈ, ព្រះឥន្ទ្រាធិរាជមានអានុភាពជាងឯង" ។ កាលីតបទៅព្រះអង្គម្ចាស់បុស្ការៈវិញថាៈ "ប្រាកដមែនហើយ ព្រះឥន្ទ្រាធិរាជទំនុកបំរុងព្រះបាទ នាលៈ ពីព្រោះស្ដេចគោរពសាសនាណាស់ ហើយដរាបណាតែទ្រង់បានប្រព្រឹត្តដោយចិត្តស្មោះស្ម័គ្រតាមប្រពៃណីដរាបនោះព្រះឥន្ទស្ថិតនៅជាមួយនឹងទ្រង់ជានិច្ច, ប៉ុន្តែ បើទ្រង់ធ្វេសប្រហែសឬប្រព្រឹត្តល្មើសវេលាណា ព្រះឥន្ទនឹងចេញចោលព្រះអង្គមិនខាន ពេលនោះព្រះបាទនាលៈនឹងធ្លាក់មកនៅក្នុងកណ្ដាប់ដៃយើង, បើដូច្នេះចូរទ្រង់ស៊ូអំណត់តទៅទៀត កុំអាលបណ្ដោយឲ្យព្រះទ័យធ្លាក់ទៅដល់អស់សេចក្ដីសង្ឃឹម" ។ ប៉ុន្តែព្រះអង្គម្ចាស់បុស្ការៈ លែងជឿពាក្យកាលីទៀត ។ ជួនកាលដោយនឹកឃើញគ្មានរំពឹងនឹងបានសោយរាជ្យក្នុងប្រទេសនិសធៈ ទ្រង់តូចព្រះទ័យដល់ទៅទ្រង់ព្រះកន្សែង ។

*

* *

វគ្គ ទី ១៥

ថ្ងៃមួយ ព្រះបាទ នាលៈ ព្រះនាង ទមយន្តី នឹងព្រះរាជបុត្រ ទាំងពីរនាំគ្នាលេងបរបាញ់សត្វ ។ ព្រះបាទនាលៈធ្វើជាសិង្ហ ព្រះនាង ទមយន្តី នឹងព្រះរាជបុត្រធ្វើជាព្រាន ។ មិនយូរប៉ុន្មាន ល្បែងនោះនាំឲ្យ សប្បាយអស្ចារ្យ ព្រះរាជបុត្រាទ្រង់បញ្ចេញសេចក្តីក្លាហាន ទោះឮ សូរសិង្ហគ្រហឹមសម្បើមយ៉ាងណាក៏នៅតែចូលលុក ។ ឯព្រះរាជបុត្រី ទ្រង់វៃឆ្លាសណាស់ ព្រះនាងប៉ិនប្រសប់ធ្វើអន្ទាក់យ៉ាងចំណានទុក ដាក់សិង្ហ បើសិង្ហជាប់អន្ទាក់ហើយមិនងាយនឹងចេញរួច ។ ព្រះបាទ នាលៈ នឹងព្រះនាងលុះឃើញស្នាព្រះហស្តព្រះរាជបុត្រដូច្នោះ ទ្រង់សព្វ ព្រះរាជហឫទ័យពន់ពេក ។ សិង្ហនឹងព្រានប្រដេញគ្នាពេញតែឧទ្យាន នៅពេលដែលព្រានចាប់ក្បាលសិង្ហបាន ទ្រង់ព្រះសំរួលលាន់ឮរំពង ។

ព្រះអាទិត្យផ្អៀងសំយុងទៅទិសបស្ចិម ប៉ុន្តែល្បែងនៅតែលេង តទៅទៀត ។ បន្តិចទៅ រាត្រីទម្លាក់ស្បៃខ្មៅគ្របផែនដីងងឹតស្លុង ; កាលនោះព្រះនាងទមយន្តីគិតខ្លាចព្រះរាជបុត្រអស់កម្លាំង ក៏នាំព្រះរាជ-បុត្រចូលទៅក្នុងប្រាសាទ ព្រះបាទនាលៈទ្រង់យាងចូលដែរ តែយាង ទាំងស្តាយល្បែង ។ ព្រះបាទនាលៈទ្រង់មានសេចក្តីរីករាយនឹងដោយ បានពិនិត្យឃើញព្រះរាជបុត្រីមានសេចក្តីក្លាហាននឹងប្រាជ្ញាវៃឆ្លាត ។ ប្រហែលជាព្រះបាទ នាលៈ ទ្រង់មិនដែលជួបនូវសេចក្តីរីករាយដូច ថ្ងៃនេះ ។

នៅយប់នោះ ព្រះអង្គម្ចាស់ប៉ុស្ការៈឃើញកាលីមកទៀត, អាទិទេព សើចបញ្ចេញចិត្តសាហាវៈហើយនិយាយទៅកាន់ទ្រង់ថា: "ប៉ុស្ការៈ! ប៉ុស្ការៈ! ប៉ុស្ការៈ! ទ្រង់មុខតែបានសប្បាយហើយ បងទ្រង់ទើបតែនឹងប្រព្រឹត្តល្មើសលើពួកអមតបុរស" ។

- "បងខ្ញុំមិនមែនជួយខ្ទោះទេ ឯងកុហកខ្ញុំទៀតហើយ" ។

- "ទេ ព្រះបាទនលៈរវល់តែលេងកំសាន្តនឹងព្រះរាជបុត្រ ទាល់តែភ្លេចពេលសូត្រធម៌នមស្ការព្រះអាទិទេព ។ នឹងថយពេលព្រះបាទនលៈមិនទាន" ។

ព្រះអង្គម្ចាស់ប៉ុស្ការៈ ស្តាប់ពាក្យកាលីហើយក៏មានសេចក្តីត្រេកអរពន់ពេក ហើយពោលហ៊ឹមៗ ថា: "ស្តេចសោយរាជ្យ! អញបានជាស្តេចសោយរាជ្យ!" ។

អាទិទេពនិយាយទៀតថា: "ឥឡូវត្រូវទ្រង់ស្តាប់បង្គាប់យើងៈ ស្អែកនេះ កុំភ្លេចទៅតាំងស្កាត់ផ្លូវស្តេច, យើងមិនជឿថា ក្នុងខណៈនេះព្រះបាទនលៈប្រកែកទៀតទេ" ។

- "ខ្ញុំស្តាប់ឯង ខ្ញុំស្តាប់បង្គាប់ឯង ដែលជាអាទិទេពមានរិទ្ធិ" ព្រះអង្គម្ចាស់ប៉ុស្ការៈអរណាស់ សើចផង លោតផង ហើយនិយាយតិចៗផងថា: "អញជាស្តេចសោយរាជ្យ! អញធ្វើជាស្តេចសោយរាជ្យ!" ។

*
* *

## វគ្គទី ១៦

ស្អែកឡើងព្រះអង្គម្ចាស់ប៉ុស្ការៈ ទ្រង់យាងទៅជិតស្ដេច ហើយទូលថាៈ "ប្រហែលជាទ្រង់ទើបនឹងជំនុំការណ៍អ្វីមួយដ៏សំខាន់ឬ? ព្រោះព្រះភមប្រែបដូចជាអស់ព្រះកាយពល តើព្រះអង្គសព្វព្រះរាជហឫទ័យនឹងលេងជាមួយទូលព្រះបង្គំបានមួយស្របក់ឬទេ? នុ៎ះហ្ន៎ឡុកឡាក់" ។

ព្រះបាទនាលៈទ្រង់ប្រែបរួញពមួយស្របក់ រួចមានព្រះបន្ទូលថាៈ "ឡុកឡាក់! បងធ្លាប់លេងឈ្នះគាលពីមុន ហើយបងខានលេងយូរណាស់មកហើយ ដូច្នេះប្អូនមកលេងជាមួយនឹងបង ប៉ុស្ការៈចូរយកគ្រាប់ឡុកឡាក់មក" ។ ពួកអ្នកតាមហែព្រះអង្គទាំងប៉ុន្មាន នាំគ្នាធ្ងល់នឹងការសម្រេចព្រះទ័យរបស់ទ្រង់ ។ ព្រះបាទនាលៈទ្រង់គង់ចាប់យកគ្រាប់ឡុកឡាក់ ហើយមានព្រះបន្ទូលថាៈ "បងដាក់ចិញ្ចៀននេះ!" ហើយទ្រង់បោះចិញ្ចៀនមួយដ៏វិចិត្រ ទៅមុខព្រះអង្គម្ចាស់ប៉ុស្ការៈ ។ ឡើងគង់នៅខាងមុខព្រះបាទនាលៈ ដោយគ្មានប្រញាប់ប្រញាល់ទេ ។ នៅពីក្រោយព្រះបាទនាលៈ ព្រះអង្គម្ចាស់ទតឃើញកាលី ទ្រង់យល់ថា មានតែទ្រង់មួយទេដែលមើលឃើញអាទិទេព ។ លុះលេងបន្តិចទៅ ចិញ្ចៀននេះ បានទៅលើព្រះហស្ដព្រះអង្គម្ចាស់ប៉ុស្ការៈ ។

ព្រះបាទនាលៈមានបន្ទូលថាៈ "ទើបតែចាញ់ម្ដងទេ បងគង់តែឈ្នះវិញ ដល់គ្រាក្រោយ, យើងលេងម្ដងទៀត" ។

ម្តងនេះព្រះបាទ នាលៈ ដោះកងដែលទ្រង់នៅព្រះសូវងដាក់ក្បាល់, ទ្រង់ចាប់ឡុកឡាក់បោះទៅ, ព្រះអង្គម្ចាស់ប៉ុស្ការៈបោះក្រោយ កងនោះក៏បានទៅព្រះអង្គម្ចាស់ប៉ុស្ការៈ ៕ ព្រះបាទនាលៈមានបន្ទូលថា "លេងទៀត" ។

ព្រះបាទនាលៈបេះតែលេងៗ ទាល់តែចាញ់អស់គ្រឿងអលង្ការនឹងសស្ត្រាវុធទាំងប៉ុន្មានដែលជាប់នៅនឹងព្រះអង្គ ។ បន្ទាប់មក ទ្រង់ក្រោកឡើងហើយមានព្រះបន្ទូលទៅកាន់ព្រះអនុជថា "ឯងហេងណាស់ល្ងាចនេះ ឯងយកគ្រឿងមាសពេជ្រនឹងសស្ត្រាវុធនេះទៅចុះ ស្អែកប្រហែលជាបងមានរាសនាល្អ មើលទៅ" ។

ព្រះរាជាស្តេចយាងទៅជិតព្រះនាងទមយន្តី ដែលទ្រង់សំកុកចាំព្រះអង្គដោយទ្រង់ព្រះកន្សែងផង ។

*
* *

## វគ្គទី ១៧

ថ្ងៃបន្ទាប់មក ក្រោយពីការប្រឹក្សារដ្ឋមន្ត្រី ព្រះនាងទមយន្តីរង់ចាំព្រះភស្តាទៀត លុះព្រះនាងទន្ទឹងមើលផ្លូវមិនឃើញ ស្តេចយាងមកសោះ ព្រះនាងគិតថា: "ព្រះស្វាមីអញប្រហែលជាវល់លេងនឹងទ្រង់ប៉ុស្ការៈដូចពីម្សិលមិញទៀតហើយ, `យី! អ្នកកំណាចនេះនឹងក្បួចអញទេដឹង?

ឥឡូវនេះ តែព្រះភស្ដាចេញឆ្ងាយពីអញៗ ចេះតែមានចិត្តព្រួយ ចុះស្ដេចកំណាចនេះនៅធ្វើអ្វីក្នុងព្រះរាជមន្ទីរដែលរចនាដោយទឹកមាសនោះ?” ។

ព្រះនាងមានបន្ទូលហៅនាងមលវិកា (Malavika) ដែលជាស្នំជំនិត ហើយប្រាប់ថា: “មលិកា! ចូរឯងទៅមើល តើស្ដេចរវល់ធ្វើអ្វី បើឯងឃើញស្ដេចកំពុងលេងជាមួយព្រះអនុជ ចូរឯងក្រាបទូលព្រះអគ្គកុំលាក់សេចក្ដីព្រួយរបស់អញចំពោះទ្រង់, ខ្ញុំព្រួយចិត្តពេកណាស់ ឱនាងមលវិកាជាទីពេញចិត្តអើយ! ចូរឯងរត់ឲ្យឆាប់ ទៅនាំស្ដេចជាទីស្រឡាញ់ដែលបោះបង់ចោលខ្ញុំ មកឲ្យខ្ញុំវិញ’ ។

នាងមលវិកាក៏ធ្វើតាមបង្គាប់ព្រះនាង, ព្រះរាជបុត្រទាំងពីរព្រះអគ្គក៏យាងចូលមករកព្រះមាតា ។ ព្រះនាងទ្រង់ថ្នមឱបកូនហើយមានព្រះបន្ទូលថា: “កូនសំឡាញ់ម្ដាយ! បិតាកូននៅឯណា? ម្ដាយព្រួយបារម្ភណាស់, កូនសំឡាញ់ឱបម្ដាយមកកូន! ម្ដាយត្រូវការទ័ងស្និទ្ធស្នាលរបស់កូន” ។

ព្រះនាងទ្រង់ប្រុងចាំព្រះសណ្ដាប់នូវសំនួរទាំងឡាយ “ម្ដេចបានជានាងមលវិកាត្រឡប់មកវិញ? ទៅរកស្ដេចឃើញឬមិនឃើញ? តើបានទូលស្ដេចហើយឬនៅ?” ។ បន្តិចស្រាប់តែព្រះនាងមានបន្ទូលសួរថា “មលវិកាឬ?” ។ នាងមលវិកាចូលមកតែឯង ដោយមានទឹកមុខជ្រប់ស្រពោន ហើយទូលព្រះនាងថា: “ឱម្ចាស់ក្សត្រីដ៏ប្រសើរ!

ខ្ញុំម្ចាស់បានឃើញព្រះអង្គ ខ្ញុំម្ចាស់បានទូលព្រះអង្គហើយ ប៉ុន្តែព្រះអង្គគ្មានទ្រង់ព្រះសណ្ដាប់ខ្ញុំម្ចាស់ទេ, ដឹងជាទ្រង់ឮខ្ញុំម្ចាស់ទូលឬមិនឮទេ, ទ្រង់បោះឡុកឡាក់ហាក់ដូចជាមនុស្សវិកលចរិត, ទ្រង់បើកព្រះនេត្រតែនៅពេលដែលទ្រង់ដាក់របស់ជាកក់ប៉ុណ្ណោះ, ទ្រង់បេះតែបាញ់ អស់គ្រឿងមាសពេជ្រ អស់អាវុធពីព្រះអង្គ, ទ្រង់ដាក់ព្រះរាជរថ១ បានទៅទ្រង់ប៉ុស្ការៈ, ទ្រង់ដាក់សេះ១ បានទៅប៉ុស្ការៈ, ពួករាជមន្ត្រីនៅឈរមើលទ្រង់ដោយមានសេចក្ដីបារម្ភជាខ្លាំង គេបានអង្វរសូមឲ្យទ្រង់ឈប់ក្រសាល ប៉ុន្តែព្រះករុណាធ្វើជាគជាថ្លង់, ទ្រង់បេះតែបរាជ័យបាញ់ ហើយទ្រង់បេះតែក្រសាលតទៅទៀត គេបារម្ភក្រែងទ្រង់វង្វេងស្មារតី" ។

ព្រះនាងទមយន្តី ចង់បញ្ចេញសេចក្ដីក្លាហាន ទើបខំទប់ទឹកព្រះនេត្រហើយទ្រង់យាងដោយស្រួលទៅកាន់ព្រះរាជមន្ទីរ ដែលព្រះករុណាកំពុងតែបាញ់អស់ទ្រព្យសម្បត្តិ ។ ពួករាជមន្ត្រីឃើញព្រះនាង ក៏កើតសេចក្ដីសង្ឃឹម ។ ព្រះនាងមានបន្ទូលដោយសូរសៀងស្រទន់ថា: "ព្រះអង្គជាទីស្នេហាប្អូន! សូមស្ដេចយាងទៅ ព្រះអង្គជ្រាបស្រាប់ហើយថា ខ្ញុំម្ចាស់ស្រឡាញ់ព្រះអង្គណាស់" ។ ព្រះរាជាទ្រង់គ្រាន់តែក្រឡេកមើលព្រះនាងដោយកាយមាយ ហើយទ្រង់បោះឡុកឡាក់ទៀត ។

(មានត)

## ដំណឹងតាមខ្យល់គ្មានភាន្តារៈ

# លោកផេង-ជ្រីវ សាស្ត្រាចារ្យនៅសាលាគរុវិជ្ជាភ្នំពេញ

### ប្រែពីភាសាបារាំងមកជាភាសាខ្មែរ

(តមក)

---

ហេតុនេះ នៅខាងបច្ចិមប្រទេស ក៏ដូចនៅខាងបូព៌ាប្រទេសដែរ បំណងស្រីក្រមុំគ្រប់រូបមិនជាផ្សេងពីគ្នាប៉ុន្មាន ។

កាមរាគនៃនារីអាយុដប់ប្រាំបីឆ្នាំ មិនគឺជាបទកាព្យឃ្លោងមួយយ៉ាងល្អបំផុតក្នុងលោក? គឺជាកាមរាគនឹងបទកាព្យដូចគ្នា គេមិនចាំបាច់គិតអំពីប្រស្នាអាកាសធាតុមជ្ឈដ្ឋានផ្សេងៗ គ្នាឡើយ, ក្រោមមេឃស្រុកណាក៏ដោយ កាមតណ្ហានិងបំណងរបស់មនុស្ស មានសភាពដូចគ្នាទាំងអស់ ។ គឺជាសេចក្តីស្នេហានិងសេចក្តីទុក្ខតែងមានដូចគ្នា ។

នាងអាតស្យាតា មានរូបសម្បត្តិចង់រកកល់ធ៌េតជាងប្អូនបន្តិច តែនាងប្រែទៅជាអន់ល្អ មកពីគ្មានសម្ផស្សសម្បត្តិដែលជាវត្ថុមួយដ៏សំខាន់បំផុតខាងស្នេហ៍មុខ ។ សេចក្តីវិបត្តិដែលជាភារៈនៃនាងតែងធ្វើទុកមុខឲ្យអន់ចុះទៅជាសោះកក្រស់ឥតជាតិ នាំកំឯករសេចក្តីបំណងឯងៗ ខឹងធ្វើសេចក្តីក្លាហានយ៉ាងខ្លាំងឲ្យស្កុនដំណើរ ។ កាមរាគត្រូវប្រគល់ឋានៈខ្លួនទុកឲ្យសេចក្តីអាណិតវិញ ។

នារីទាំងពីរ មួយដឹកមួយ នាំគ្នាត្រាច់តាមមាគ៌ាដ៏បង្អៀត មាន សុទ្ធតែដើមកប្បាសព្រៃនឹងស្មៅអណ្តាសដុះក្បែរខាង ៗ ហ្វូងពពែស្គម រង្វៀត ឃើញតែឆ្អឹង រត់ត្រកៗ ពីមុខនាង ឆាកបោចស្មៅធ្ងន់ស្គាំស៊ី បណ្តើរ ៗ នាងឡូឡា កំពុងដេញពពែ ស្រែកច្រៀងទំនុកមួយយ៉ាង ពីរោះគួរគាប់ណោចអធម្ម ដូចជាអ្នកគង្វាលពពែឯទៀតធ្លាប់ច្រៀងបណ្តើរ ពពែដែរ គឺជាទំនុកតែព្រកាលណាបណ្តាលឲ្យរលឹកស្រុកកំណើត នឹង នាំឲ្យកើតមានសេចក្តីតម្រេក ៗ បម្រៀងនេះហាក់ដូចជាហើររៅហើរ- មកតែកង្វាលកន្តារៈ នឹងលើវាលខ្សាច់ក្នុងនៃបូព៌ាប្រទេស តាំងពីប៉ុន្មាន សតវត្សមកហើយ គឺថ្ងៃអំពីវាលខ្សាច់ដ៏ក្តៅ នៅក្រោមចំហាយព្រះ អាទិត្យ នឹងសេចក្តីត្រជាក់ក្រោមក្លានកង់កន្តារវនភូមិ ៗ

គឺជាទំនុកកាព្យមួយដែលច្រៀងតាំងពីដើមដល់ចុង ដោយប្រើសំ- ឡេងតែមួយបែប ទំនុកនេះតែងធ្វើឲ្យអ្នកដែលប្រកបដោយការសង្កេត ច្រើនជាប់ចិត្តនិយាយមិនកើត មានសេចក្តីរីករាយជាសុខុមភាព ព្រម ទាំងសេចក្តីព្រួយបិទមុខ គឺដូចជាធុជារសផ្អែមលាយជូរចត់ បើនិយាយ ដោយសង្ខេប គឺជារសជាតិនៃជីវភាពមួយយ៉ាងដែលប្រកបដោយសេចក្តី បំណងមិនចេះពេញនឹងសេចក្តីសុខស្រួលចាប់មិនជាប់ ៗ

ចំណែកនាងឡូឡា កំពុងតែច្រៀង ដោយសូរសៀងដ៏ពីរោះបរិសុទ្ធ រលាក់បទញ័រទទាក់ដូចរ៉ៃហូរធ្លាក់ចេញពីជ្រោះ ស្រាប់តែឮសូរសេះ-

ផាយ ៗ នារីទាំងពីរប្រាណទប់ទ័ក ក្ដៅក្រៃត ៗ សេះកាន់តែផាយជិតមក ៗ សូរជើងសេះខ្លាំងពេក ស្ទើររបើកដីផ្លូវដែរឯ ៗ នាង-អាឥសុរាគា ជាស្រីស្គាល់តែព្រយនឹងសេចក្ដីលំបាក ស្ទុះចាប់ឧបទ្រុងប្អូនជាប់ ញាក់សាច់ទទើក ទាញកន្សែងបិទមុខជិត ហើយស្រែកថា: "ឡូឡា! អញភ័យណាស់! អញភ័យណាស់! គេមកធ្វើទុក្ខយើងហើយ" ៗ

នាងឡូឡាប្រាប់ថា: "កុំភ័យអីបង! ប្រហែលអ្នកដំណើរ ឬក៏អ្នកជិះសេះវង្វេងផ្លូវទេ" ៗ

ខណៈនោះ ស្រាប់តែឃើញសេះមួយសម្អាត មានមនុស្សម្នាក់ពាក់ខ្លួស់ល្មម ជិះនៅពីលើ លេចចេញមកត្រង់ផ្លូវបត់ ៗ

ឃើញដូច្នោះ នាងឡូឡាកិតភ័យខ្លាំងទំស្រែក ព្រោះឃើញសំលៀកបំពាក់ជារបៀបអឺរុប នាងដឹងថាអ្នកបរទេស គឺមនុស្សដែលជនជាតិអាហ៊្វប់តែងស្អប់ខ្ពើមជាទីបំផុត ៗ នាងទាញក្រមាបិទមុខភ្លាម ចាប់ទាញដៃបងមកប្រាប់ថា: "មក! យើងពួន! ឆាប់ឡើង! យើងត្រូវពួន!" ៗ

ពាំពាបែកខ្វែកគ្នាអស់ នារីពីរនាក់ឧបគ្នាទៅវិញទៅមក នាំគ្នាពួននៅខាងក្រោយគុម្ពផ្កាកូឡាបដើមយ៉ាងរហ័ស តែអ្នកជិះសេះបានឃើញស្ត្រីទាំងពីររូបស្រេច ៗ

អ្នកនេះបង្អន់ល្បឿនសេះ ទាញឲ្យដើរ ៗ ហើយបរចូលសំដៅគុម្ពឈើដែលយុវតីកំសត់ទាំងពីររំព្រឹងពួន ដោយនឹកស្មានថាជាសាសន៍ម៉ាំងមករកធ្វើទុក្ខ ៗ លុះចូលទៅជិត នៅប្រហែលពីរ-បីម៉ែត្រនឹងដល់ អ្នកដំណើរលោតចុះពីខ្នងសេះភ្លែត ៗ រស្មីព្រះអាទិត្យដែលជិតចូលរន្ធទាំងមកចំមុខគេ មានភាពបែបសង្ហា ៗ អ្នកដំណើរនេះ គឺតួអ៊ីស្មាអ៊ីលបេនអៃយ៉ាជ ៗ

អ៊ីស្មាអ៊ីលចូលទៅជិតនារីទាំងពីរ យកដៃស្ទាបស្មានាងឡើងឡើ ហើយសួរដោយមធុរវាចាថា: "ហេតុអ្វីគឺបិទមុខអូន!" ៗ

នាងក្រមុំមិនឆ្លើយ ៗ

អ៊ីស្មាអ៊ីល ដណ្ដឹងទៀតថា: "អូនឯងភ័យ!" ៗ

បងប្អូនពីរនាក់នេះតែឱបគ្នាញញ័រខ្លួន មិនហ៊ានក្រមើក ៗ

ខណ:នោះ អ៊ីស្មាអ៊ីល ចាប់ទាញសំពត់ដែលបិទមុខចេញ ៗ នាងចំងាកមុខគេចួនទៀត អ៊ីស្មាអ៊ីលយកដៃទាំងពីរចាប់មុខបំបែរមកវិញ ហើយសំឡឹងមួយស្របក់ មិននិយាយអ្វីដោយការប្រើដិតឲ្យតកងរូបសម្បត្តិដ៏បរិសុទ្ធ ៗ គេដឹងថានាងមានភ័យញ័ររំប្រប់ ៗ

នាងអង្វរថា: "សូមលោកកុំធ្វើបាបយើងខ្ញុំ!" ៗ

អ៊ីស្មាអ៊ីលឆ្លើយតបថា: "សូមព្រះអាឡស់ជួយនាងឲ្យបានសុខ! បងឈ្មោះអ៊ីស្មាអ៊ីល ជាកូនច្បងលោកអៃយ៉ាជ ជាកាអ៊ិត អ្នកគ្រប់គ្រង

ក្រង់កាស៊ិ កាក-ប៊ូលី!" ។ រួចអ៊ីស្មាអ៊ីលលែងមុខនាងទៅវិញ ។

ចំណែកនាងក៏បាត់ភ័យ ព្រោះដឹងប្រាកដជាសាសន៍ជាមួយគ្នា ។ នាងឆ្លើយតបប្រាប់ទៅវិញថា: "ខ្ញុំឈ្មោះឡីឡាជាគណៈអាព៉ប់ដើរទេសនៃលោក តាម៉ា ព្រុកអែលតាឌី" ។ រួចនាងលើកដៃចង្អុលប្រាប់ទីសំណាក់អាស្រ័យ ដែលក្រឡេកទៅមើលឃើញលីមៗ ដោយពន្លឺព្រះអាទិត្យជិតយប់ ។

នាងឡីឡាប្រាប់បងថា "មិនមែនបច្ចាមិត្រទេ" ។ នាងអាឥស្សាតាក៏ព្រមសុខចិត្តបើកមុខឡើងវិញ ។ អ៊ីស្មាអ៊ីលសួរទៀតថា: "ហ្នឹងបងផងនាងឬ?" ។ នាងឡីឡាឆ្លើយដំកបថា: "ចាបងស្រីខ្ញុំ ឈ្មោះអាឥស្សាតា គាត់ខ្មាក់ក្អែកទេ" ។ អ៊ីស្មាអ៊ីលមានសេចក្តីអាណិតខ្លោចចិត្ត ។ គេប្រឹងនឹកនិយាយសំដីដែលធ្វើឲ្យកើតចិត្តក្លាហាន ទីងសំដីជាមិត្តភាព តែពាក្យមិនស្តាប់បង្គាប់គេសោះ គឺមិនព្រមធ្វើតាមគំនិតខាងក្នុង យោបល់ទាំងប៉ុន្មានទៅជាច្របូកច្របល់លាយឡំគ្នាអស់ រកនិយាយមិនកើត នៅតែគំនិតមួយទេដែលធំជាងគេ ដែលធ្វើឲ្យជាក់ច្បាស់ក្នុងចិត្តរបស់គេ គឺសេចក្តីស្នេហាចំពោះរូបសម្បត្តិរបស់នាងក្រមុំ ប្រកបដោយទឹកមុខថ្លាស្រស់ដ៏បរិសុទ្ធ នៅព្រហ្មចារីយ៍ ។

អ៊ីស្មាអ៊ីលដែលមិនអាចទប់ទល់នឹងសម្ផស្សសម្បត្តិនេះ មិនមែនដូចបណ្តាជនខ្លះក្នុងស្រុកទេ គឺមកពីមិនបានជាគិតប្រុងទុក ព្រោះគេ

គាស្រ័យនៅក្នុងបច្ចិមប្រទេសជាយូរឆ្នាំ ។ គេបានប្រទះនារីមួយរូប ស្អាតនៅក្បែរវាលកន្តារៈនេះ គឺជាការណ៍មួយដែលនាំឲ្យគេព្រឺព្រួចក្នុងដួងវិញ្ញាណព្រមទាំងតប់ប៉ម៉ល់ផង ។

រូបស្រាប់តែសេចក្តីឆ្ងតកើតមានដល់ចិត្តគេភ្លាម ព្រោះនឹកឃើញដល់អង្គកាយខាងក្នុងរបស់នាងដែលទទេ សាច់ខ្ចីសដូចបណ្តូលចេកយ៉ាងម៉ដ្ឋផង់ ដែលតែងធ្វើឲ្យជនានុជនជ្រប់ចិត្តវិលខួរក្បាលគ្រប់គ្នា តែតម្រេកនេះកើតឡើងមួយភ្លែតដូចផ្លេកបន្ទោរ ហើយក៏បាត់ទៅវិញ គេឱនក្បាលគំនាប់នាងក្រមុំផែលឡើងលើសេះយ៉ាងប្រញាប់ ហើយបំផាយសំដៅវាលខ្សាច់កន្តារៈ ប្រហែលស៊ីស្មាស៊ីលខ្លាចក្រែងទឹកក្តៅគឺកាមរាគជ្រមុជគេ ដូចជាទឹកជ្រៅជ្រមុជអ្នកដំណើរមាត់សមុទ្រ ប្រហែលខ្លាចក្រែងគេប្រទូស្តដល់សាយណ្ហសម័យដ៏បរិសុទ្ធ នឹងព្រហ្មចារីយរបស់កុមារីនោះទេដឹង ម្យ៉ាងទៀត, ប្រហែលជាមានកុសលចេតសិកណាមួយជាគ្រឿងកាំងចិត្តដែលគេបានហាត់បង្ហឹកពីប្រទេសអឺរ៉ុបមក ។

ចំណែកសូរជើងសេះដែលផ្ទាយហាក់ដូចជាជាប់នៅក្នុងដួងវិញ្ញាណនៃនាងឡឺឡា ជានិច្ច ។

(មានត)

# បរិយាយពីសិល្បៈខ្មែរ

## លើកទី ៣

## របស់លោក ចាប-ពិន

កាលពីថ្ងៃទី ១០ កុម្ភៈ ១៩៥៤ នេះ ខ្ញុំបានបរិយាយពីសិល្បៈខ្មែរ ជូនជាសណ្ដាប់បងប្អូនរួមជាតិ ជាលើកទី២, ឥឡូវនេះ សូមបរិយាយពីសិល្បៈខ្មែរលើកទី ៣ ទៀត មានសេចក្ដីដូចតទៅនេះ ៖

នាដសិល្បៈ (សិល្បៈខាងរាំ) គីតសិល្បៈ (សិល្បៈខាងច្រៀង) ហើយនឹងតូរ្យាង្គសិល្បៈ (សិល្បៈខាងភ្លេង) ជាសិល្បៈមានលក្ខណៈប្លែកពីសិល្បៈដទៃ គឺជាសិល្បៈងាយរលត់ជាងសិល្បៈទាំងពួង ។ ប្រាង្គណ៍ ប្រាសាទ វិហារ ជាដើម ដែលគេសាងសង់ឡើង ហៅថា ស្ថាបនកម្ម, ភាពគំនូរ ឬ ភាពក្បាច់ដែលគេគូរឬឆ្លាក់ឡើង ហៅថា រចនាកម្ម, រូបស្និត ដែលគេសិតឡើង ហៅថា បដិមាកម្ម, សៀវភៅដែលគេតែងឡើង ហៅថា វណ្ណកម្ម ។ សិល្បៈពួកនេះ កាលគេបានធ្វើឲ្យសម្រេចរូបពេញលក្ខណៈឡើងហើយ តែងនៅឋិតថេរបានយូរ មិនងាយរលត់ឆាប់ទេ ។ ឯសិល្បៈខាងច្រៀង សិល្បៈខាងរាំ សិល្បៈខាងភ្លេងឬខាងនាដសិល្បៈ ជាសិល្បៈឆាប់រលត់ កាលបើសិល្បិនជាអ្នកសំដែងបានសំដែងស្រេចហើយ ក៏ហើយគ្នា ក្រៅពីការស្ដាប់ ការមើល ការចាំ

នៅក្នុងចិត្ត ឥតអ្វីនៅសល់ឲ្យឃើញឲ្យឮបានទេ បើចង់ឃើញចង់ឮទៀត ត្រូវតែឲ្យសិល្បិនសំដែងឲ្យមើលឲ្យស្ដាប់ជាថ្មី ដែលអាចល្អ ឬអាក្រក់ជាងមុនក៏បាន មិនគង់នៅជាទៀងទាត់ ដូចសិល្បៈខាងគំនូរ ចម្លាក់ ស្ថិត សៀវភៅទេ ទាំងសិល្បិនអ្នកសំដែងសិល្បៈប្រភេទនេះ ក៏ចាញ់ប្រៀបសិល្បិនអ្នកសំដែងសិល្បៈប្រភេទដទៃ ៗ

អំពីបុរាណមក ព្រះមហាក្សត្រជាអគ្គឧបត្ថម្ភសិល្បៈរបស់ជាតិ ពួកសិល្បិនដែលនៅក្នុងព្រះបរមរាជូបត្ថម្ភ មិនបាច់កង្វល់ក្នុងការចិញ្ចឹមជីវិតឡើយ បើមានសមត្ថភាពក្នុងសិល្បៈរបស់ខ្លួនហើយ ក៏បានជាជនដែលព្រះរាជាទ្រង់ចិញ្ចឹម ទ្រង់ព្រះរាជទានឋានន្តរស័ក្តិតាមសមត្ថភាពរៀងខ្លួន, ព្រោះហេតុនេះបានជាសិល្បៈបេះតែចម្រើនឡើង ដូចព្រះបន្ទូលខាងដើម ។ ព្រះរាជការៈខាងទំនុកបម្រុងសិល្បៈរបស់ជាតិក្នុងបច្ចុប្បន្ននេះ ធ្លាក់មកជាមុខងាររបស់ជាតិចិញ្ចឹម គឺជាតិត្រូវជាអ្នកទទួលភារៈនេះជំនួស, ហេតុនេះយើងគ្រប់រូបដែលរួមគ្នាជាជាតិមួយ ទើបមានមុខងារជាអ្នកត្រូវព្យាយាមរក្សាទីងតន្ត្រីតំណសិល្បៈរបស់ជាតិស្នងព្រះរាជការៈ ដែលធ្លាក់ចំមកលើយើង, បើជាតិគឺយើងទាំងអស់គ្នាមិនអើពើ មិនធ្វើមុខងារនាទីជាអ្នកចិញ្ចឹមទេ សិល្បៈរបស់ជាតិក៏រស់នៅពុំបាន ត្រូវតែសាបសូន្យទៅ ដូចព្រះបន្ទូលខាងលើនោះ, បើប្រសិនជាសាបសូន្យទៅ ក៏កំហុសរបស់យើងគ្រប់គ្នា នឹងបន្ទោសនរណាពុំបានទាំងអស់ ត្រូវតែបន្ទោសខ្លួនយើង

ព្រោះការព្យាបាលសិល្បៈដែលជាអារ្យធម៌របស់ជាតិ ឲ្យបានឋិតថេរនឹងចំរើនល្អនោះស្រេចនៅលើប្រជាជនជាពលរដ្ឋ ។

ប្រទេសខ្មែរយើង ព្រះរាជរដ្ឋាភិបាលបានបង្កើតសាលាបង្រៀនសិល្បៈខ្មែរខាងផ្នែកវិជ្ជាស្ថាបត្យកម្ម គឺវិជ្ជាសំណង់ វិជ្ជារចនាកម្ម គឺវិជ្ជា-គំនូរ ឬចម្លាក់ វិជ្ជាបដិមាកម្ម គឺវិជ្ជាស្មិត ព្រមទាំងវិជ្ជាតំបាញ វិជ្ជាជាងមាស ជាងប្រាក់ ដែលជាសិល្បៈហាវៈឋិតថេរនៅបានយូរ សន្មតឈ្មោះសាលានេះថា "សាលាវិចិត្រសិល្បៈខេមរៈ" បានបើកឲ្យយុវជនខ្មែរដែលស្ម័គ្រស្មោះចំពោះសិល្បៈដូចពោលខាងលើ ចូលរៀនបានដោយសេរី ឈ្មោះថាព្រះរាជរដ្ឋាភិបាលប្រគល់ការនេះ ឲ្យក្រុមសិល្បករព្យាបាលជំនួសប្រជាជនរួមជាតិ ដើម្បីរក្សាសិល្បៈខ្មែរតបវេណីខ្មែរ; យុវជនខ្មែរទាំងប្រុសទាំងស្រីបានចូលរៀនវិជ្ជាសំណង់ វិជ្ជាគំនូរ វិជ្ជាចម្លាក់ វិជ្ជាស្មិត វិជ្ជាតំបាញ វិជ្ជាជាងមាស វិជ្ជាជាងប្រាក់ បេះស្ទាត់ប្រឡងចេញតាមឆ្នាំដែលសាលាកំណត់ទុក បានជាប់សញ្ញាបត្រ បានចេញទៅប្រកបវិជ្ជាជីវៈ ដោយសិល្បៈនេះ តែរៀងខ្លួនមានចំនួនច្រើន នាំឲ្យចំរើនប្រទេសជាតិហើយ; នៅតែផ្នែកគីតសិល្បៈ នាដសិល្បៈ និងតូរ្យាង្គសិល្បៈដែលជាសិល្បៈរលត់ឆាប់នោះ ពុំទាន់មានសាលាបង្រៀននៅឡើយ ម្ល៉ោះហើយពួកសិល្បិន គឺពួកអ្នកច្រៀងក៏ចេះតែច្រៀងតាមចំនើនខ្លួនក្លាយចាកបទដើម ស្មើរតែបាត់រូបបទខ្មែរ ដែលជាបទធ្លាប់

មានលំអមកពីបុកណា, ព្រោះហេតុនេះ បានជាឯកឧត្តមទាំងពីររូប គឺឯកឧត្តម សម - ញាណ ទៅក្រសួងធម្មការ សិល្បការ នឹងឯកឧត្តម ប៉ាក់ សារិន ទៅក្រសួងឃោសនាការ បានសន្ទនាគ្នាអំពីសិល្បៈខ្មែរ ដូចរំពណ៌នាពីមុននោះ បានសម្រេចថានឹងព្យាយាមរក្សាទុកនូវបវេណី គឺតសិល្បៈខ្មែរ ព្រមទាំងពង្រីកឲ្យរីកសាយ ឲ្យចំរើនថែមឡើងទៀត ដើម្បីរក្សាទុកនូវបម្រៀងខ្មែរ ដែលជាសិល្បៈតាប់រលត់មិនឲ្យរលត់ងាយ នឹងមិនឲ្យក្លាយទៅជាដទៃ ដែលមិនមែនជាគីតសិល្បៈខ្មែរ ។

ឯកឧត្តម សម ញាណ រដ្ឋមន្ត្រីក្រសួងធម្មការ សិល្បការ មាន យោបល់យល់ឃើញថា បើប្រសិនជា "សាលាវិចិត្រសិល្បៈខេមរៈ" មិនអណ្តែតចុះ អណ្តែតឡើង មួងទៅចូលក្រសួងនោះ មួងទៅចូល ក្រសួងនេះ តាក់ឬសជាប់នៅតែក្នុងអាគារបស់ក្រសួងធម្មការបិតថេរទៅ ឯកឧត្តមប្រុងនឹងបង្កើតឲ្យមានសាលាបង្រៀន វិជ្ជាភ្លេង វិជ្ជារាំ វិជ្ជា-តូរ្យតន្ត្រី នឹងវិជ្ជាមហោស្រព ឲ្យវិជ្ជាទាំងនេះ បែរមុខទៅកាន់ វឌ្ឍនភាព ដោយមានតាំងសភាមួយ ហៅថា "សភាវឌ្ឍនធម៌" សម្រាប់ពង្រីកសិល្បៈរបស់ជាតិឲ្យចំរើនដូចអារ្យប្រទេសនានា ។

បញ្ចប់ការបរិយាយត្រឹមប៉ុណ្ណោះ ។

បន្ទាប់ពីនេះ បានចាត់ហ្វឹងពេហារ សែម ឲ្យច្រៀងចាប៉ីតាមអត្ថបទក្នុងសៀវភៅច្រៀងជាតិនិយម ដាក់វិទ្យុសំឡេងប្រទេសកម្ពុជា នៅថ្ងៃទី ២៥ កុម្ភៈ ១៩៥៤ ជាសណ្តាប់បងប្អូនរួមជាតិ ដើម្បីរក្សាទុកនូវប្រពៃណីគីតសិល្បៈខ្មែរ ឲ្យគង់វង្សនឹងឲ្យចម្រើនជាកិរិយាការតទៅ ៗ

---

## បរិយាយពីសិល្បៈខ្មែរ

លើកទី ៤

## របស់លោក ចាប-ពិន

កាលពីថ្ងៃទី ២៥ កុម្ភៈ ១៩៥៤ នេះ ខ្ញុំបានបរិយាយពីសិល្បៈខ្មែរ លើកទី ៣ ជូនជាសណ្តាប់បងប្អូនរួមជាតិហើយ ឥឡូវនេះ សូមបរិយាយពីសិល្បៈខ្មែរលើកទី ៤ ទៀត មានសេចក្តីដូចតទៅនេះ៖

គ្រឿងបរិភោគ គ្រឿងស្លៀកដណ្តប់ នឹងទីនៅអាស្រ័យ សុទ្ធតែជារបស់ចាំបាច់ដល់ជីវិតមនុស្ស ហើយជារបស់សំខាន់ដែលមនុស្សយើងត្រូវតែមានប្រចាំរូបគ្រប់គ្នា ទាំងជាតិដែលចម្រើន នឹងមិនទាន់ចម្រើន សូម្បីតែជាតិដែលនៅជាជាតិព្រៃផ្សៃនៅឡើយ ក៏ត្រូវតែមានជាធម្មតា, ប៉ុន្តែជាតិណាដែលធ្វើរបស់អំបាលនេះបានយ៉ាងប្រណីតមានរបៀបរៀបរយល្អជាងជាតិដទៃ គេហៅជាតិនោះថាជាជាតិមានសេចក្តី

ចម្រើនខ្ពស់ គឺវឌ្ឍនធម៌ខ្ពស់ សម្រាប់ជាតិរបស់គេដែលធ្វើឲ្យជាតិគេចម្រើន ។ កិច្ចការរបស់ក្រុមសិល្បករជាកិច្ចការទាក់ទងដោយ វឌ្ឍនធម៌របស់ជាតិ ។

វត្ថុដែលគេស្ថាបនាឡើង បានយ៉ាងប្រណីតល្អមានរបៀបរៀបរយនោះ លោកហៅថា "សិល្ប" ហេតុនេះ សិល្បៈទើបជារបស់កើតពីមនុស្សសាងឡើង; បើកើតឡើងឯងៗ តាមធម្មជាតិ ដូចផ្កាឈើដែលកើតនៅក្នុងដើមវាពីកំណើតមក មិនចាត់ជាសិល្បៈទេ, ជាក្បីដែលគេធ្វើដាក់នៅទីងសំពត់អាវ ឬគ្រឿងស្លៀកដណ្ដប់ជាដើម ទើបចាត់ជាសិល្បៈ ។ សិល្បៈបែបនេះហៅថា " សិល្បៈបរយុគ " គឺសិល្បៈដែលប្រើគួបជាមួយនឹងរបស់ដទៃ, សិល្ប.បរយុគធ្វើឲ្យយើងជាអ្នកបានស្លៀកដណ្ដប់ល្អ នៅអាស្រ័យល្អ បរិភោគល្អ ដូចអាហារដែលចាត់ការធ្វើឡើងដោយថ្វីដៃដ៏ជំនាញ ទឹងមានសេចក្ដីប្រណីតល្អ កាលគេធ្វើស្រេចហើយគេទុកដាក់យ៉ាងរៀបរយល្អក្នុងកែវ៖ ក្នុងចាន ឬក្នុងភាជន៍ដ៏ស្អាតហ្មត់ចត់ ហើយភាជន៍នោះមានសម្រស់ស្រស់ល្អ ដោយសម្បុរដោយក្បាច់ផ្កាក្បីត្រកាលក្អែកក៏តែតែៈធ្វើអាហារនោះ ឲ្យគួរបង់បរិភោគថែមឡើងទៀត. ដែលធ្វើឲ្យល្អដូច្នេះបាន ក៏ដោយសារសិល្បិនជាអ្នកធ្វើនោះមានសមត្ថភាព បានសំដែងចំណេះដែលជាសិល្បៈក្នុងអាហារ ទឹងក្នុងភាជន៍នោះ ទើបធ្វើឲ្យអាហារនោះជារបស់គួរបង់បរិភោគទឹងភាជន៍នោះជារបស់គួរបង់ប្រើប្រាស់ទៅបានយ៉ាងជាក់ស្ដែង ។

នៅមានសិល្បៈមួយចំពូកទៀតខ្ពស់ជាងសិល្បៈបរយុគ ព្រោះជាសិល្បៈមិនមែនធ្វើឡើងដើម្បីបរិភោគ ដើម្បីប្រើប្រាស់ទេ គឺធ្វើឡើងដើម្បីបន្ទុងចិត្ត (សម្រើបចិត្ត) ដើម្បីលើកទឹកចិត្តមនុស្សឲ្យខ្ពស់ ឲ្យមនុស្សដែលបានឃើញហើយអាចគិតអាចប្រព្រឹត្តតែចំណែកល្អ ។ សិល្បៈបែបនេះ លោកហៅថា "វិចិត្រសិល្បៈ" នានាជាតិគេយល់គេប្រកាន់ថាសិល្បៈប្រភេទនេះជារបស់ខ្ពស់ ព្រោះជាគ្រឿងបញ្ចេញមុខបញ្ចើចក្អករបស់ជាតិ, សិល្បិនដែលធ្វើសិល្បៈបែបនេះឲ្យមានឡើងយ៉ាងល្អប្ញសំដែងសិល្បៈបែបនេះយ៉ាងល្អបានគេប្រកាន់ថា ជាអ្នកមានកិត្តិយស ៗ នាដសិល្បៈ (សិល្បៈខាងរបាំ) ក៏ជាសាខាមួយរបស់វិចិត្រសិល្បៈ ការធ្វើ ប្ញសំដែងសិល្បៈបែបនេះក៏ជាការមានកិត្តិយស ៗ តែមុននេះអ្នកផងសំគាល់ការច្រៀង ការរាំ និងការលេងភ្លេង ថាជាការមិនសូវមានថ្លៃ ៗ តាមពិត ការច្រៀង ការរាំ និងការលេងភ្លេង មិនមែនជារបស់ថោកទាបដូចមនុស្សសាមញ្ញយល់នោះទេ គឺជារបស់ខ្ពង់ខ្ពស់ដែលសាកលលោកតែងលើកដំកើង តែងរាប់អានថាជាសិល្បៈសំខាន់សម្រាប់ប្រទេសជាតិឲ្យកិត្តិយសដល់សិល្បិនអ្នកសំដែងសិល្បៈនេះយ៉ាងប្រសើរ និងឲ្យកិត្តិយសដល់ប្រទេសជាតិយ៉ាងឧត្តម ៗ

ពួកទេសចរនៅនានាប្រទេស ដែលគេបានមកកាន់ប្រទេសយើង គេតែងត្រូវការមើលរបាំរបស់យើង មានល្ខោនជាដើមដែលមានព្រម

ទាំងកំ ទាំងប្រៀន ទាំងភ្លេង ដើម្បីកំសាន្តចិត្តនឹងដើម្បីសាកមើលអារ្យ-ធម៌យើង ថាមានពលភាពខ្ពស់ត្រឹមណា, ទាំងយើងវិញ កាលបើមានអ្នកបរទេសធំៗ គេមកកាន់ប្រទេសយើង ក៏សំដែងរបាំយើងដែលជាសិល្បៈសម្រើបចិត្តបង្ហាញគេ ដើម្បីជាគ្រឿងកំសាន្តបន្ទំតគេជាភ្ញៀវដែលជាមិត្តនឹងយើង ៗ ព្រោះហេតុនេះពួករបាំខ្មែរយើងគួរតែបានទទួលការអប់រំជាផ្លូវការ ឲ្យជំនាញឲ្យមានឋានៈខ្ពស់ មានកិត្តិយសសមតាមកាលៈទេសៈកុំឲ្យអន់ជាងរបាំជាតិដទៃ ៗ

ប្រទេសខ្មែរយើង ព្រះរាជរដ្ឋាភិបាលបានបង្កើតសាលាបង្រៀនជាផ្លូវការសម្រាប់បង្រៀនខ្លះវិជ្ជាសិល្បៈទាំងឡាយហៅថា "សាលាវិចិត្រសិល្បៈខេមរៈ" បានបង្រៀនវិជ្ជាខាងបរយុគសិល្បៈ គឺវិជ្ជាក្បាច់របនាគំនូរ ចម្លាក់ ស្មិត គ្រឿងឥដ្ឋ ស៊ុមង៉ មាស ប្រាក់ នឹងជំបាញ តាមបែបបុរាណនឹងបែបទំនើបហើយ, នៅតែវិជ្ជាខាងវិចិត្រសិល្បៈ គឺវិជ្ជាមហោស្រព របាំ ចម្រៀង ភ្លេង តន្ត្រី ដែលជាសិល្បៈសម្រើបចិត្ត មិនទាន់មានសាលាបង្រៀនជាផ្លូវការនៅឡើយ ៗ

សព្វថ្ងៃ សាលាវិចិត្រសិល្បៈខេមរៈ នៅក្នុងបន្ទុកក្រសួងធម្មការសិល្បការ, ឯកឧត្តម សម-ញាណ រដ្ឋមន្ត្រីក្រសួងនេះ នឹងឯកឧត្តមប្រាក់-សារិន អនុរដ្ឋលេខាទទួលបន្ទុកខាងឃោសនាការ បានសន្ទនាគ្នាអំពី

សិល្បៈខ្មែរ រិះរកមធ្យោបាយរៀបចំសិល្បៈខ្មែរឲ្យលូតលាស់ចម្រើន បានទាំងចាត់ឲ្យខ្ញុំមកបរិយាយពីសិល្បៈខ្មែរនិងចាត់ឲ្យហ្លួងពេហារ សែម មកប្រៀនចាប៉ីពល់ថ្ងៃសីលជាគម្រប់ ២ លើក និងលើកនេះហើយ, តែតទៅថ្ងៃមុខ ប្រហែលជាព្រះរាជរដ្ឋាភិបាលនឹងដាក់សាលាវិចិត្រសិល្បៈខេមរៈ, ទៅក្នុងបន្ទុកក្រសួងសិក្សាធិការជាតិវិញ, កាលបើដូច្នេះក្រសួងធម្មការក៏អស់ភារៈក្នុងរឿងសិល្បៈ, ទាំងខ្លួនខ្ញុំដែលជាអ្នកបរិយាយពីសិល្បៈជំនួសឯកឧត្តមទាំងពីររូប ក៏អស់បានមកបរិយាយពីរឿងនេះប្រស័យជាមួយបងប្អូនរួមជាតិតទៅទៀត, តែក្រសួងធម្មការសង្ឃឹមនឹងទុកចិត្តលើក្រសួងសិក្សាធិការជាតិ ជាមុខជានឹងព្យាយាមចាត់ការយ៉ាងណាឲ្យការងារវិចិត្រសិល្បៈខ្មែរ បានលូតលាស់ចម្រើនឡើងជាងមុនពុំខាន ។

បញ្ចប់ការបរិយាយត្រឹមប៉ុណ្ណេះ ។

បន្ទាប់ពីនេះ បានចាត់ហ្លួងពេហារ សែម ឲ្យប្រៀនចាប៉ីតាមអត្ថបទក្នុងសៀវភៅច្បាប់ប្រដៅកូនចៅខ្មែរ ពណ៌នាពីជាតិ, សាសនា, មហាក្សត្រ ដែលចាត់ទុកជាទំនុកបម្រៀនជាតិនិយម ដាក់វិទ្យុសម្លេងប្រទេសកម្ពុជា នៅថ្ងៃទី ៣ មីនា ១៩៥៤ ជាសណ្តាប់បងប្អូនរួមជាតិ ដើម្បីរក្សាទុកនូវបវេណីគីតសិល្បៈខ្មែរឲ្យគង់វង្ស និងឲ្យបម្រើនជាកិយ្យា គាតតទៅ ។

# បរិយាយពីប្រវត្តិសិល្បៈខ្មែរ

លើកទី ៥

## របស់លោក ហាប-ពិន

ក្នុងនាមឯកឧត្តម សម - ញាណ រដ្ឋមន្ត្រីក្រសួងធម្មការ និងការសិក្សាធម៌វិន័យព្រះពុទ្ធសាសនា ខ្ញុំសូមបរិយាយពីប្រវត្តិសិល្បការខ្មែរ មានដំណើរសេចក្ដីដូចតទៅនេះ៖

កាលពីថ្ងៃសុក្រទី ៥ មីនា គ. ស. ១៩៥៤ នេះ គណៈរដ្ឋមន្ត្រីបានជួបជុំពិចារណាសេចក្ដីព្រាងព្រះរាជក្រឹត្យមួយ ស្ដីពីការដាក់ចាត់ការសិល្បការ គឺសាលាវិចិត្រសិល្បៈខេមរៈ ឲ្យទៅនៅក្នុងបន្ទុកក្រសួងសិក្សាធិការជាតិ ។

លទ្ធផលនៃការពិចារណា គណៈរដ្ឋមន្ត្រីបានព្រមព្រៀងជាឯកច្ឆន្ទតាមសេចក្ដីព្រាងព្រះរាជក្រឹត្យដូចថ្លែងខាងលើ ។

នៅពេលជួបជុំពិចារណានោះ ឯកឧត្តម សម ញាណ បានជូនគណៈរដ្ឋមន្ត្រីនូវកំណត់ហេតុពិសេសមួយ ស្ដីពីប្រវត្តិសិល្បការ មានសេចក្ដីដូចខាងមុខ៖

ប្រវត្តិរបស់សិល្បការនេះ ដូចទ្រង់និងឯកឧត្តមទាំងឡាយជ្រាប ហើយថាឋិតនៅពុំទៀងទាត់ទេ ចួនណានៅក្នុងបន្ទុកក្រសួងធម្មការ ប៉ុន្តែពុំបានយឺនយូរ ក៏ត្រូវបញ្ចេញពីក្រសួងនេះទៅនៅក្នុងបន្ទុកក្រសួងសិក្សា-

ធិការជាតិ នៅពុំបានយូរប៉ុន្មានក៏ត្រឡប់មកនៅក្នុងក្រសួងធម្មការវិញ នាំឲ្យគាត់អ្នកលពុំអាចនឹងពង្រីកឲ្យធំទូលាយទៅបាន ប៉ុន្តែតាំងពីពេលនេះទៅ សិល្បការនេះ ចេញទៅនៅក្នុងបន្ទុកក្រសួងសិក្សាធិការជាតិ ប្រហែលជាប់ជាយូរអង្វែងតទៅ ។

ហេតុនេះ ទូលបង្គំ ខ្ញុំ សូមលើកយកសិល្បការមកលាតត្រដាងថ្វាយ, ជូនគណៈរដ្ឋមន្ត្រីជ្រាបថា៖

ទី ១) សិល្បការ ឬសិល្បៈនេះ ចែកជា ២ ប្រភេទ គឺ

ក) ថាវរសិល្បៈ = សិល្បៈមិនឆាយរលត់ បានខាងក្បាច់របនាគំនូរ ។ល។

ខ) អថាវរសិល្បៈ = សិល្បៈឆាប់រលត់ បានខាងមហោស្រព ឬរបាំ ។ល។

ទី ២) សិល្បៈ ចែកជា ២ ប្រភេទទៀត គឺ

ក) បរយុគសិល្បៈ = សិល្បៈប្រកបនឹងវត្ថុដទៃ បានខាងក្បាច់របនាដែលធ្វើដាក់នៅវត្ថុផ្សេងៗ ។ល។

ខ) វិចិត្រសិល្បៈ = សិល្បៈដែលវិចិត្រឡើងដើម្បីសម្រើបចិត្ត បានខាងមហោស្រព ឬរបាំ ។ល។

ទី ៣) វិចិត្រសិល្បៈ បើហៅតាមចំណែកៗ មាន ៣ យ៉ាង គឺ

ក) ការរាំ ជានាដសិល្បៈ,

ខ) ការច្រៀង ជាគីតសិល្បៈ,

គ) ការលេងភ្លេង ជាតូរ្យាន្តសិល្បៈ ។

តែថាបើហៅដោយរួបរួម ថា នាដសិល្បៈ តែម្យ៉ាងក៏បាន ព្រោះការរាំតែងតែមានច្រៀង មានភ្លេងត្រូវគ្រឿងជាដរាប ។

រួមទាំងអស់នេះ ហៅថា "សិល្បការ" ។ ប្រទេសកម្ពុជាយើងគួរតែរៀបចំសិល្បការទាំងអស់នេះឲ្យបានចម្រើន ដូចបុរាណសម័យដែលធ្លាប់ល្បីឈ្មោះមកហើយ ។

ឥឡូវនេះ សិល្បការ ត្រូវដាក់ឲ្យទៅនៅក្នុងបន្ទុកក្រសួងសិក្សាធិការជាតិ តាំងពីថ្ងៃទី ៥ មីនា គ.ស. ១៩៥៤ នេះទៅ. កាលបើសិល្បការបានចូលទៅនៅក្នុងបន្ទុកក្រសួងសិក្សាធិការជាតិហើយ អស់លោកទាំងឡាយជាភ្នាក់ងារក្រុមសិល្បការ ក៏ត្រូវអញ្ជើញទៅនៅក្នុងបន្ទុកក្រសួងនោះផង ។

ដូច្នេះ ខ្ញុំសូមជូនដំណើរអស់លោកក្រុមសិល្បការដែលធ្លាប់នៅធ្វើការក្នុងក្រសួងធម្មការជាមួយនឹងខ្ញុំ សូមអស់លោកអញ្ជើញទៅធ្វើការក្នុងក្រសួងសិក្សាធិការជាតិឲ្យបានសេចក្ដីសុខសេចក្ដីចម្រើនជាកិយោភាពតទៅ ។

---

## បុណ្យមាឃបូជានៅសាលាស្រុកក្រូចឆ្មារ

## ធឹងបន្ទាយក្រូចឆ្មារ

## ព្រះមហា ជា-អឿន និស្សិតសាលាបាលីជាន់ខ្ពស់

រៀបរៀង

---

សាលាស្រុកក្រូចឆ្មារ កាលពីថ្ងៃអង្គារ ១៤ កើតខែមាឃ ឆ្នាំម្សាញ់ ព. ស. ២៤៩៦ គឺទី ១៦ កុម្ភៈ ឆ្នាំ ១៩៥៤ មានពិធីបុណ្យមាឃបូជា ។ ពួកភ្នាក់ងារប៉ូលិស បានចាត់ចែងទីកន្លែងមានក្រាលអាសនៈជាដើម សម្រាប់ប្រជុំពុទ្ធបរិស័ទ ដើម្បីធ្វើសក្ការបូជា ក្នុងគេហដ្ឋានលោកចៅហ្វាយស្រុក មានតាក់តែងទង់ជាតិទង់សាសនា, មេភ្លើងអគ្គិសនីភ្លឺព្រោងព្រាតពេញទីលានសាលាស្រុក, ហើយមានតាក់តែងកន្លែង ១ ប៉ែកទៀតមិនជិតមិនឆ្ងាយពេកទេ ល្មមតែឮភ្លេងទៅដល់ ជាកន្លែងសម្រាប់ប្រជារាស្ត្រលេងល្ខោនកំសាន្ត ក្រោយពេលទេសនា មានរថយន្តឃោសនា ១ ទៀតរបស់កុមារពេទ្យ បន្ទរពីងសំឡេងថាសម៉ាស៊ីនភ្លេងទ្រហឹងអឺងកង ។ លុះពួកពុទ្ធបរិស័ទជួបជុំគ្នាហើយ ទើបអាចារ្យសម្រាប់បុណ្យតាំងផ្តើមសូត្រធម៌នមស្សការធ្វើវត្តព្រះ បន្ទាប់មកអារាធនាសីល - ព្រហ្មតាមបែបបទ ។ ក្នុងទីសន្និបាតនេះ ព្រះញាណកោសល ញាណ-ឈឹង ផ្តើមសំដែងធម៌ទេសនា ដកស្រង់សេចក្តីដែលមានខ្លឹមសារ គឺសំដែងអំពីជាតិ - សាសនា - មហាក្សត្រិយ៍

នាំឧទាហរណ៍ប្រៀបធៀបគតិលោកគតិធម៌ ពីពេះគេក្បាលក្បាយគួរឲ្យចង់ស្តាប់ ដោយរំពងសំឡេងទំគេក្បាលសនសព្វ ចាប់តាំងពីម៉ោង ២១ ដល់ម៉ោង ២៣ យប់ទើបចប់ ។ បន្ទាប់មកពួកលោនប្រុស ៗ លេងកំសាន្តរហូតដល់ម៉ោង ១-២ អធ្រាត្រទើបលើកលែង ។

ដល់ម៉ោង ១០ ព្រឹកថ្ងៃ ១៥-កើតខែមាឃ ទី ១៧ កុម្ភៈ ឆ្នាំ ១៩៥៤ លោកស្រី គីង-ពូន បានចាត់ចែងភោជនប្រគេនព្រះសង្ឃប្រើនអង្គឆាន់កងសាលាស្រុកនោះ ។

មុនពេលឆាន់ ព្រះសង្ឃដែលនិមន្តមកពីវត្តនានាមានលោកគ្រូអនុគណស្រុកក្រូចឆ្មារជាប្រធាន បានសូត្រធម៌កត្តានុមោទនា ។ វេលានោះព្រះញាណកោសល ញាណ-ឈឹន ថ្លៀតយកឱកាសនេះថ្លែងទៅលោកគ្រូអនុគណដោយថេរដីកាថា "សូមទោសលោកគ្រូម្ចាស់! ការសូត្រធម៌អម្បាញ់មិញនេះ មិនមានរបៀបចុះសំរុងគ្នាសោះ ទំនងជារៀនតាមវត្តខុសគ្នា; ការណ៍ដែលមិនចុះរបៀបគ្នានេះ ខ្ញុំករុណាស្តាយណាស់, សូមលោកគ្រូជ្រាបថា ពុទ្ធសាសនបណ្ឌិត្យ សាលាបាលីជាន់ខ្ពស់ទីងសាលាបាលីរង រាជការអនុញ្ញាតតាំងឲ្យមានឡើងដើម្បីបណ្តុះផ្លូវសិក្សាឲ្យល្អតលាស់ ចំរើនទីងឲ្យការប្រតិបត្តិមានរបៀបរត់របទតែបែបដូចគ្នា; សព្វថ្ងៃនេះ ព្រះករុណាជាម្ចាស់ជីវិត ទីងរាជរដ្ឋាភិបាលកំពុងឧបត្ថម្ភដោយម៉ឺងម៉ាត់ណាស់, សូមលោកគ្រូក្រែនរំលឹកឲ្យភិក្ខុ

សាមណេរស្រុកនេះ ចូលទៅរៀនសូត្រនឹងគេ ឬក៏នាំគ្នាតាំងសាលាបាលីរង សាលាធម្មវិន័យគ្រប់ៗវត្តឡើង ទើបជាការងាយស្រួលដល់ការចេះដឹង នឹងប្រតិបត្តិតាម ៗ មួយវិញទៀត កាលបើមានឱកាសជួបជុំគ្នាមួយដងមួយគ្រា ដូចយ៉ាងថ្ងៃនេះត្រូវសូត្រធម៌ជារបៀបកណ្ដាលតាមបែបបទសាលាបាលីដែលរាជការបានរៀបចំនោះវិញទើបស្រួលព្រោះមានសៀវភៅគម្ពីរសុទ្ធតែអ្នកប្រាជ្ញបានពិនិត្យផ្ទៀងផ្ទាត់ហើយស្រាប់ ងាយដឹងងាយយល់បានបុណ្យច្រើនផង ពីរោះស្ដាប់ផង ហើយជាការស្រួលដល់អស់លោកមន្ត្រីខេត្ត - ស្រុកឃុំខ្លះ សូត្រតាមផងបាន ដ្បិតអស់លោកទាំងនោះច្រើនចេះចាំតាមសៀវភៅគិហិបតិបត្តិ សូមលោកអាចារ្យសម្រាប់វត្តនានាខំជួយជំកុំជំកើង រក្សាតម្លៃព្រះពុទ្ធសាសនា តម្លៃមន្ត្រីខេត្ត-ស្រុក-ឃុំ ឲ្យមានថ្លៃថ្នូរខ្ពង់ខ្ពស់សមឋានៈជាប្រទេសឯករាជ្យ, ទាំងអស់លោកអ្នកមន្ត្រីសាលាខេត្ត ស្រុក-ឃុំ ទៀតសោត សុំឲ្យធ្វើការប្រស្រ័យទាក់ទងនឹងព្រះសង្ឃគ្រហស្ថ ដើម្បីឲ្យកើតសេចក្ដីស្និទ្ធស្នាលរាប់រកគ្នាទៅ" ៗ

លំដាប់នោះ លោកនួន ទីយោក្យ ត្រុតលេខនៅសាលាស្រុកក្រូចឆ្មារ ព្រនូបាលទោ ឌុម-ផាន់ នឹងមន្ត្រីស្រុកទាំងឡាយ បានប្រគេនពរសព្ទសាធុការតបវិញថា "ព្រះគុណអើយ! ថេរដីការំលឹកផ្ដាំផ្ញើនេះពីរោះណាស់ៗ យើងខ្ញុំសូមទទួលចាំទុកតទៅ" ៗ

បន្ទាយក្រុបផ្ការ កាលនៅថ្ងៃ ១៥ កើតខែមាឃ ទី ១៧ កុម្ភៈ ឆ្នាំ ១៩៥៤ មានទាហានទាំងនាយតូច-ធំជាច្រើននាក់ រៀបចំទីកន្លែងបុណ្យយ៉ាងឧឡារិកអធិកអធម្ម ដូចនៅសាលាស្រុកដែរ មានទីកន្លែងសម្រាប់លេងល្ខោនកំសាន្ត មានរថយន្តឃោសនាកុមារពេទ្យ ចាក់ថាសម៉ាស៊ីនភ្លេងឮសូរសំឡេងក្រាំងក្រៃ មានពួកឈ្មួញលក់ដូររបស់ផ្សេងៗជាច្រើនពេញទាំងបន្ទាយចង្អៀតជ្រៀតជើងគ្នាដើរស្ទើរតែពុំរួច ។

ឯបន្ទាយក្រុបផ្ការនេះមាន ២ ថ្នាក់ គឺថ្នាក់លើនិងថ្នាក់ក្រោម ។ ទាំងពីរថ្នាក់នេះ សឹងពោរពាសដោយពួកសប្បុរសប្រុស-ស្រីចាស់ក្មេងខ្ទាន់ខ្ទាប់ត្រៀបត្រាទាំងជាន់លើជាន់ក្រោម ។ ម៉ោង ២០ ព្រះសង្ឃចំរើនព្រះបរិត្ត ម៉ោង ២១ សំដែងធម៌ទេសនា ។ ក្នុងទីសន្និបាតនេះក៏ព្រះញាណកោសល ញាណ-ឈឹង ទេសនាទៀត គឺលោកសំដែង

១. អំពីពិធីមាឃបូជា ព្រមទាំងនាំឧទាហរណ៍ដ៏ជ្រាលជ្រៅ ដែលមានក្នុងគម្ពីរមហាបរិនិព្វានសូត្រ មកប្រៀបធៀបផលនៃការធ្វើសក្ការៈបូជា ជាបវេណីធម៌មួយសម្រាប់អ្នកកាន់ពុទ្ធសាសនា គួរធ្វើដោយសុទ្ធចិត្តពល់ៗរូប ។

២. អំពីបែបបទសណ្តាប់ធ្នាប់កងយោធាទាហាន ព្រមទាំងអធិប្បាយអំពីឧត្តមគតិ លទ្ធផលនិងករណីយកិច្ចដែលកងយោធាត្រូវតែបំពេញយ៉ាងទូលាយ ដោយការអង់អាចតស៊ូខានពុំបាន ដរាបដល់អវសាននៃជីវិតភាពរៀងៗខ្លួន ។

៣ .- អំពីជនអ្នកមានសេចក្ដីកតញ្ញូកតវេទី ជីងគុណធ្វើតបគុណលោក ព្រមទាំងអធិប្បាយប្រៀបធៀបហេតុផលដ៏ខ្ពង់ខ្ពស់ ដែលអ្នកដឹងគុណត្រូវទទួលចំណោយ ទាំងក្នុងឥធលោកបរលោក ដោយមានភ័ស្តុតាងជាច្រើនរឿង មកពន្យល់ដោយថេរដីកាពីរោះផ្អែមល្ហែម គួរឲ្យកើតសេចក្ដីជ្រះថ្លាក្រៃលែង ។ ចាប់តាំងពីម៉ោង ២១ ដល់ម៉ោង ២២ ទើបចប់ ។

លុះចប់ហើយពួកពុទ្ធបរិស័ទសូត្រប្រកាសផ្សាយផលបន្ត បន្ទាប់អំពីនោះ ពួកល្ខោនកំលេងកំសាន្តរហូតដល់យប់ជ្រៅ ព្ទស្គរសំឡេងហោកព្រៀវអឺងកងទាំងបន្ទាយក្របធារ ។

ដល់ព្រឹកឡើងលោក ឌុម-ផាន់ អ្នកស្រីទីងពួកសប្បុរសជួបជុំដាក់បាត្រព្រះសង្ឃ ១០៨ អង្គ ។ បន្ទាប់មក ពួកជាងថតរូបមកថតរូបឧត្តមបុរសទាំង ៤ នាក់គឺ ព្រះតេជគុណ ព្រះញាណកោសលញាណឈឺន, លោកស្រី-ណាល់ ចៅហ្វាយស្រុកក្របធារ, លោក ឌុម-ផាន់ នាយព្រៃនូបាលទោ, លោកមហាផា-អៀន និស្សិតសាលាបាលីជាន់ខ្ពស់ ទុកជាអនុស្សាវរីយ៍ ។